369 Broadway St., Lowell, MA 01854
Tel: 978-454-7578, 978-454-7507

Open Daily: Sun. to Thurs. 11:00 AM to 1:00 AM
Fri. and Sat. 11:00 AM to 3:00 AM

យើងអាចយកម្ហូបទៅដល់ផ្ទះបាន
We Deliver All Day: 11:30 AM to 1:00 AM Available to most areas.
Min. $10.00 Delivery Charge $2

$17.99

បង្គងឆាខ្ទឹម និងខ្ញីពិសេស
SPECIAL 2 Lobsters w/ Scallion & Ginger



សូមអញ្ជើញមកលំហែរអារម្មណ៍
កំចាត់ភាពអាប់អួរ!

ភែសផ្ទះដ្ឋាន ហ្សៀ

Bar's Open
Monday-Saturday
10a.m.–2a.m.
Sunday
11a.m.–2a.m.

198 W. Godfrey Avenue.
(Corner of Godfrey & 2nd St.)

Philadelphia, PA 19120
215-621-7563

ហាងមាសខ្មែរអង្គរ
KHMER ANGKOR JEWELRY

Since 1983
Certified Diamonds & Diamond Jewelry

18K & 24K Gold, Platinum Jewelry & Watches
GIA Graduate Gemologist on Staff
Authorized RADO & LONGINES Dealer
Repairs Done on Premises

Open
Tuesday-Sunday
10:30AM-6:30PM
Closed Monday

600 Washington Avenue. Unit 12B. Philadelphia, PA 19147
Tel. 215-599-2222 Fax. 215-599-2223

For more infromation
contact: Molyka Tieng
@ 978.322.8768
www.lowellwaterfestival.com

15th Annual



Save The Date: August 19th-20th,

ពិធីបុណ្យទន្លេ

งานแข่งเรือสายสัมพันธ์ประจำปีที่

Designed by: S.Uch

Vihi insurance-Income Tax Mortgage-Realty

ធានារ៉ាប់រង_តាក់លើប្រាក់ចំណូល_ខ្ចីប្រាក់ទិញផ្ទះ_ទិញលក់ផ្ទះ

Insurance ធានារ៉ាប់រង
(Licensed PA, NJ & DE) អាជ្ញាប័ណ្ណ PA, NJ & DE
Home • ផ្ទះ Car • រថយន្ត
Business • មុខរបរ Health • សុខភាព

Income Tax តាក់លើប្រាក់ចំណូល
Individual • ផ្ទាល់ខ្លួន Business • ពីមុខរបរ
Pay Roll • ពីប្រាក់ខែ
Forming New Business • បង្កើតមុខជំនួញថ្មី
Home Deed Transfer • ប្តូរឈ្មោះផ្ទះ
Auto Title Transfer • ប្តូរឈ្មោះម្ចាស់រថយន្ត

Vihi Mortgage Vihi ខ្ចីប្រាក់ទិញផ្ទះ
(Licensed by PA Dept. of Banking)
Hiep Vo, MBA, President.
Finance/Refinance your home
Low interest Rate & Down Payment
Fast Preapproval

- អាជ្ញាប័ណ្ណពី PA ការិយាល័យធានាគារ
- ហីប វ៉ូ MBA ប្រធាន
- ផ្តល់ប្រាក់កម្ចីក្នុងការទិញផ្ទះទិញដំបូង ឬកណ្តាលទី
- ការប្រាក់ថោក និងលុយកក់តិច
- ចម្លើយល្បឿន

Vihi Realty Co
Dr. Hanh Vo, Broker/Owner Cell (267) 664-2689
Buy & Sell Properties & Businesses
Visit: www.drhanh.net for more foreclosure homes

North Phila – 215-276-8441
5225 N. 5th Street
Phila., Pa 19120

South Phila – 215-336-0600
1519 W. Passyunk Ave.
Phila., Pa 19145
www.vihifinancial.com

ហាងមាសស្មី

SUNSHINE JEWELRY, INC.
215-271-2950

Certified Diamonds & Golds (24K & 18K)
Men & Women Jewelries & Watches
Custom Design & Repairs on Premise
15 Years in Services & Growing Strong

702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com

Phở Hà Saigon

Vietnamese Restaurant

7 days A Week
9am-9pm

B.Y.O.B.

ជាហាងដែលធ្វើ ហ្វើ ឆ្ងាញ់ជាងគេនៅហ្វីឡាដែលហ្សៀ
ចុងភៅដែលពូកែធ្វើ ហ្វើ និងម្ហូបផ្សេងៗឯទៀត
ត្រូវមាត់ហ្សៀរគ្រប់ៗរូប ឥឡូវនេះមកធ្វើម្ហូបនៅហាងយើងខ្ញុំ
ហើយធានាថា ម្ហូបអាហារហាង Phở Hà Saigon
និងបំរើលោកអ្នកបានយ៉ាងពេញចិត្តគ្រប់ពេលវេលា



320 W. Oregon Avenue, Suite 1. Philadelphia, PA 19147
Tel: (215) 389-1002 (Inside Oregon Market)

VISA MasterCard DISCOVER NETWORK

បេសកម្មមនុស្សធម៌ ដឹកម្តេចម្រោសឆ្ពោះទៅកាន់ ជំរំជនភៀសសឹកនៅឯខេត្តឧត្តរមានជ័យ

●●● ក្នុងនាមជាសមាជិកនៃគណកម្មាការចម្រុះ និងក្នុងនាមជាអ្នកយកព័ត៌មានផងនោះ នៅព្រឹកថ្ងៃអាទិត្យទី១ ខែមិថុនា កន្លងមកនេះ យើង (អ៊ឹម ល្បឿម) បានបំពេញនូវភារកិច្ចដ៏ចម្បងមួយក្នុងការធ្វើដំណើរលើកំណាត់ផ្លូវដ៏វែងអន្លាយចេញពីខេត្តកំពង់ស្ពឺ ដែលជាខេត្តមួយពោរពេញទៅដោយដើមត្នោតដ៏ច្រើនជាងគេឆ្ពោះទៅកាន់ខេត្តឧត្តរមានជ័យដែលនៅទាំងនោះឆ្ពោះទៅកាន់ប្រទេសកម្ពុជា ដើម្បីធ្វើសកម្មភាពមនុស្សធម៌ដល់បងប្អូនជនភៀសសឹកខ្មែរយើងនៅឯខេត្តឧត្តរមានជ័យ ។ ថ្ងៃបុណ្យចូលឆ្នាំដំបូង (១៣ ខែ មេសា) ជាថ្ងៃដែលយើងបានឈានជើងជាន់លើមាតុភូមិកំណើតលើកទី៨ក្នុងអំឡុងពេល៩ឆ្នាំ ដែលបានមករស់នៅឯសហរដ្ឋអាមេរិក ។ ហើយនៅថ្ងៃដំបូងនោះបន្ទាប់ពីបានងូតទឹកជម្រះកាយរួចរាល់ហើយ យើងក៏បានដឹកជញ្ជូនអ្នកស្រុកមួយចំនួនធំ ដែលភាគច្រើនជាស្ត្រីមេម៉ាយ និងកុមារកំព្រា ដែលមានជីវភាពខ្វះខាតយ៉ាងខ្លាំង ទៅកាន់ទីតាំងមួយដែលមានទីតាំងនៅចម្ងាយប្រមាណ ៣ម៉ាយ ពីទីតាំងដែលយើងស្នាក់នៅ ដើម្បីចែកចាយអំណោយមនុស្សធម៌ ដែលយើងបានយកមកពីសហរដ្ឋអាមេរិក ។ ទីតាំងនោះ ត្រូវបានគេដឹងថា មានជនភៀសសឹករាប់ពាន់គ្រួសារ ដែលពួកគាត់បានចាកចេញពីផ្ទះសម្បែងទៅកាន់ទីដ្ឋានដែលពួកគាត់យល់ថា ជាកន្លែងមានសុវត្ថិភាព ។

គោលបំណងរបស់យើង គឺគ្មានអ្វីក្រៅពីកិច្ចការមនុស្សធម៌ឡើយព្រោះយើងជាខ្មែរមានបេះដូងជាខ្មែរ មានឈាមជ័រជាខ្មែរ មានសន្តានជាខ្មែរមានសាវតាជាខ្មែរ... ហេតុនេះ គឺចាំបាច់យើងត្រូវចេះជួយធុរៈគ្នាក្នុងខណៈដែលមនុស្សខ្មែរ ដូចគ្នាកំពុងមានទុក្ខអាសន្នអន់ក្រ... ។ ក៏ប៉ុន្តែមុននឹងបន្តសាច់រឿងតទៅមុខទៀត នោះក្នុងនាមជាតំណាងពលរដ្ឋខ្មែរក្នុងសហគមន៍ហ៊ីឡាដែលហ្សៀដែលបានចូលរួមធ្វើកិច្ចការមនុស្សធម៌នេះសូមឆ្លៀតឱកាសសំដែងនូវអំណរគុណដ៏អនេកប្បការចំពោះសប្បុរសជនក្នុងសហគមន៍ដ៏តូចចង្អៀតមួយនេះ ដែលបានចូលរួមជួយរំលែកធ្វើវិភាគទានសប្បុរសធម៌ដល់ជនភៀសសឹកខ្មែរយើងនៅឯ-ខេត្តឧត្តរមានជ័យ តាមរយៈការធ្វើបុណ្យទក្ខិណា-ទានមួយកាលពីពេលកន្លងមកនេះនៅឯវត្ត "ប៉ាលេលេយ្យ" នាទីក្រុងហ៊ីឡាដែលហ្សៀខាងត្បូងដែលគណកម្មការសម្រាប់បុណ្យនេះត្រូវបានបង្កើតឡើងដោយមានជាច្រើនក្រុមច្រើនបក្សនយោបាយ និងជាច្រើនវត្តអារាម ។ ទោះបីជាបច្ច័យដែលប្រមូលបាននៅសល់ត្រឹមតែ១៩៥០ដុល្លារក្តីតែនេះ បែរជាមានអត្ថន័យដ៏មហាសាលសម្រាប់បងប្អូនខ្មែរក្នុងសហគមន៍ហ៊ីឡាដែលហ្សៀដែលពោរពេញដោយក្តីសន្តោស និងអាណិតស្រឡាញ់ដល់មាតុភូមិកំណើតរបស់ពួកគាត់ និងជាមនុស្សខ្មែរដូចគ្នា ។

ដោយមានការណែនាំពីលោក "ពិន សំខុន" អគ្គនាយកការផ្សាយនៃកាសែត "ខ្មែរប៉ុស្តិ៍" និងមានការឯកភាពពីគណកម្មការចម្រុះគ្រប់រូបផង ទើបយើងត្រូវបានទទួលភារៈជាអ្នកទទួលលុយទូរស័ព្ទទៅកាន់អតីតអនិកជនខ្មែរ-បារាំងម្នាក់ឈ្មោះលោក "ស៊ូ អេងឡេង" ដើម្បីប្រគល់ថវិកាទាំង១៩៥០ដុល្លារជូនលោក ព្រោះគាត់ជាមនុស្សដែលមានការទុកចិត្តខ្ពស់ពីលោក "ពិន សំខុន" ប្រធានខ្មែរប៉ុស្តិ៍ ហើយលោកក៏ជាមិត្តភក្តិធ្លាប់ធ្វើការសង្គមជាមួយគ្នាកាលពីនៅប្រទេសបារាំង ជាពិសេសនោះគឺលោក "អេង ឡេង" នេះហើយជាប្រធានមូលនិធិ "ឆឺជី" ដែលមានន័យជាភាសាខ្មែរថា "មូលនិធិករុណាសង្គ្រោះ" ។ ដូចការរៀបរាប់របស់យើងនេះហើយទើបមានការណែនាំ និងឯកភាពក្នុងការប្រគល់ថវិការទាំងនោះទៅកាន់លោក អេងឡេង ក្នុងការចាត់ចែងទូទៅលើអំណោយមនុស្សធម៌ ។

ជាអកុសលក្នុងថ្ងៃបុណ្យចូលឆ្នាំខ្មែរនាពេលនោះលោក អេងឡេង ពុំមានវត្តមាននៅភ្នំពេញឡើយដោយអ្នកទទួលទូរស័ព្ទប្រាប់ថា "គាត់ចេញទៅក្រៅប្រទេស" ។ ប្រមាណជាមួយសប្តាហ៍ក្រោយមកទើបលោក អេងឡេង ហៅទូរស័ព្ទមករកយើងវិញ ។ មួយថ្ងៃបន្ទាប់មក ទើបយើងធ្វើដំណើរទៅកាន់ផ្ទះរបស់លោកនៅឯភ្នំពេញម្តុំស្តុបផ្សារអូឬស្សី ដើម្បីផ្ទេរលុយទាំងនោះជូនលោក ដោយមានលិខិតផ្ទេរប្រាក់ និងលិខិតទទួលដែលសរសេរដោយដៃ ។ លុះថ្ងៃបន្តបន្ទាប់មកទៀត យើងទាំងពីរបានទូរស័ព្ទទាក់ទងគ្នាជា ញឹកញាប់ ដើម្បីស្វែងរករូបមន្តល្អណាមួយ ក្នុងការចែកអំណោយព្រោះ "ថវិកាមានចំនួនត្រឹមតែ១៩៥០ដុល្លារ រីឯជនភៀសសឹកមានចំនួនច្រើន" ។ ទាំងអស់នេះជាចំណោទ និងជាបញ្ហាដែលយើងតែងតែពិភាក្សាគ្នាជាញឹកញាប់ ។ ក៏ប៉ុន្តែសម្រាប់យើងបានផ្តល់នូវឱកាសគ្រប់យ៉ាងជូនលោក អេងឡេង ក្នុងការចាត់ចែងចិញ្ចឹមសម្ភារៈសម្រាប់ជាអំណោយដល់ជនភៀសសឹកទាំងនោះ ពីព្រោះថ្វីបើលោកជាអនិកជនខ្មែរនៅប្រទេសបារាំងពិតមែន ប៉ុន្តែបច្ចុប្បន្នលោកជាអាជីវករដ៏សមរម្យម្នាក់នៅឯភ្នំពេញ ដូច្នេះលោកអាចសិក្សាដឹងយ៉ាងច្បាស់អំពីតម្លៃទំនិញដែលត្រូវទិញស្របតាមតម្លៃទីផ្សារ ។

ទីបំផុតយើងក៏បានរកច្រកចេញ ដោយការទិញអង្ករ និងកៅស៊ូប៉ាតង់សម្រាប់ជាអំណោយមនុស្សធម៌ ដោយផ្នែកខាងអង្ករជាស្បៀងរបស់បងប្អូនខ្មែរនៅហ៊ីឡាដែលហ្សៀ រីឯផ្នែកខាងកៅស៊ូប៉ាតង់ជាអំណោយរបស់មូលនិធិ "ករុណាសង្គ្រោះ" ដោយមានលោក ស៊ូ អេងឡេង ជាប្រធានមូលនិធិ ហើយក៏បានសម្រេចយកថ្ងៃទី១ ខែឧសភាជាថ្ងៃចេញដំណើរ ។

នៅថ្ងៃទី១នេះ យើងពុំបានរួមដំណើរជាមួយលោក អេងឡេង និងក្រុមរបស់គាត់ ឡើយព្រោះដោយសាររថយន្តរបស់គាត់ ចង្អៀតពេក ទើបយើងសម្រេចចិត្តជិះរថយន្តឈ្នួលដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន ហើយណាត់ជួបគ្នានៅឯសៀមរាប ។ យើងបានសម្រាកមួយយប់នៅទីនោះ លុះព្រឹកឡើងចាប់ផ្តើមចេញដំណើរតាំងពីព្រលឹមម៉ោង៦:00 ដោយមានរថយន្តពីរគ្រឿង ។ ទីមួយ គឺជារថយន្តផ្ទាល់ខ្លួន-របស់លោក អេងឡេង ជាប្រភេទ Pick-Up មួយបាំងកន្លះ និងមានមនុស្សបួននាក់នៅក្នុងនោះ ។

រីឯផ្នែកខាងក្រោយនៃរថយន្តត្រូវបានផ្ទុកទៅដោយកៅស៊ូប៉ាតង់យ៉ាងច្រើនដែលត្រូវបានចងយ៉ាងណែន និងមានសុវត្ថិភាពបំផុត ។ ចំណែកឯទីពីរជារថយន្តដែលយើងជិះដោយមានមនុស្សបីនាក់ ហើយរថយន្តនេះត្រូវបានមូលនិធិ "ករុណាសង្គ្រោះ" របស់លោក អេង ឡេង ជាអ្នកជួលឱ្យសម្រាប់យើងផ្ទាល់ ។

មកដល់ត្រង់ចំណុចនេះ យើងសូមនិយាយជម្រាបមិត្តអ្នកអាន ក៏ដូចជាសប្បុរសជនដែលជាម្ចាស់អំណោយថា គោលដៅចម្បងក្នុងបេសកកម្មមនុស្សធម៌នេះ គឺឆ្ពោះទៅកាន់វត្ត "ចូកគ្រួស" ដែលជាជំរំជនភៀសសឹកដ៏ធំជាងគេក្នុងចំណោមជំរំទាំង១១ នៅក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ ព្រោះទីនោះមានជនភៀសសឹកដល់ទៅ១៨៥៥ គ្រួសារ ។ នេះបើតាមរបាយការណ៍ក្រៅផ្លូវការពីមន្ត្រីនៃមន្ទីរអប់រំម្នាក់ឈ្មោះ "សុង"ដែលបានផ្តល់ឱ្យយើង ហើយគាត់ក៏ជាសហការីដ៏សកម្មមួយរូបដែលចូលរួមក្នុងសកម្មភាពមនុស្សធម៌ជាមួយនឹងក្រុមការងាររបស់យើង ។ ហើយតាមរយៈនៃមន្ត្រីអប់រំខេត្តដដែលនេះ លោកក៏ជាសារតាំងក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីសុំការអនុញ្ញាតដើម្បីក្រុមការងារយើងបានចែកអំណោយដល់ជនភៀសសឹក ។ ដោយយល់ថាមានការឿយហាត់ច្រើនទើបលោក សុង ត្រូវបានទទួលសាគុណចំនួន៥០ដុល្លារពីក្រុមការងារមនុស្សធម៌យើង ប៉ុន្តែលុយនោះវាជាថវិកាផ្ទាល់ខ្លួនរបស់លោក ស៊ូ អេងឡេង ប្រធានមូលនិធិ "ករុណាសង្គ្រោះ" ។ សូមជម្រាបបន្ថែមថា "មូលនិធិករុណាសង្គ្រោះ" (តទៅទំព័រទី១៦)

តមកពីទំព័រទី ១៥

បេសកម្មមនុស្សធម៌ដ៏ចម្លែង...

ជាមូលនិធិដែលមានគោលដៅផ្សព្វផ្សាយ និងពង្រឹងផ្នែកព្រះពុទ្ធសាសនានៅឯប្រទេសតៃវ៉ាន់ ។ ហើយក្នុងដំណើរបេសកកម្មមនុស្សធម៌រួមគ្នានេះ គឺមូលនិធិនេះហើយជាអ្នកចេញថ្លៃលើការហូបចុកទាំងអស់... ។

មិត្តអ្នកអានជាទីមេត្រី ដោយសារតែពេលវេលាខ្លី និងក៏មានការកំណត់ពេលដើម្បីចែកអំណោយជាស្រេចហើយនោះ ទើបរថយន្តទាំងពីរគ្រឿងរបស់ក្រុមការងារយើងបោះពួយសម្រុកទៅមុខយ៉ាងលឿនលើកំណាត់ផ្លូវកៅស៊ូដ៏រាបស្មើមួយអន្លើ និងលើផ្លូវដីក្រហមមួយអន្លើដែលម្តងម្កាលធ្វើឱ្យយើងពុំអាចចាប់ភ្នែកមើលទេសភាពដ៏ល្អត្រកាល នាពេលអរុណោទ័យបានឡើយ ព្រោះដោយសារលំអងធូលីដ៏ខ្ពស់ខ្ពាញ់កើតចេញពីការខំបោះពួយទៅមុខរបស់ក្បួនរថយន្តយោធាជាច្រើនគ្រឿងដែលដឹកសម្ភារៈសឹកឆ្ពោះទៅកាន់ខេត្តឧត្តរមានជ័យដូចក្រុមរបស់យើងដែរ ។ តែទោះបីជាយ៉ាងណាក៏ដោយទីបំផុតយើងបានទៅដល់គោលដៅដោយសុវត្ថិភាព និងតាមកាលកំណត់ពេល គឺប្រមាណជាម៉ោង៨ព្រឹក ។

ទិដ្ឋភាពនៃជំរំជនភៀសសឹកក្នុងវត្ត "ចូកគ្រួស" នាពេលព្រឹកព្រលឹមមានសភាពអ៊ូអរ ។ នៅពេលនោះយើងសង្កេតឃើញក្មេងចាស់ប្រុសស្រីគ្រប់វ័យមានសភាពស្គមស្គាំងស្គេកស្គាំងហាក់ខ្វះសារជាតិបំរុងអ្វីម្យ៉ាង ។ ក្រៅពីការជ្រកកោនក្រោមដំបូបាតង់ពណ៌បៃតងយ៉ាងរកែតរកូតហើយនោះ យើងក៏សង្កេតឃើញមានអ្នកលក់បន្លែត្រីសាច់កំប៊ុកកំប៉ុកម្រមាណជា៥-៦នាក់ដែរ ដែលនេះជាផ្នែកមួយក្នុងការសម្រួលដល់សេចក្តីត្រូវការបណ្តោះអាសន្នដល់ជនភៀសសឹកនៅទីនោះ ។ នៅពេលនោះអាជ្ញាធរមូលដ្ឋានមានការរាក់ទាក់ និងស្វាគមន៍ចំពោះក្រុមការងារយើងក្នុងនាមជាម្ចាស់អំណោយ និងអាជ្ញាធរដែនដី ប៉ុន្តែយើងមិនបានខ្ជល់មិនបានរាក់ទាក់ និងមិនគួរសមជាមួយអាជ្ញាធរទាំងនោះឡើយ ដោយទុកឱកាសផ្តល់ឱ្យចាស់ៗគាត់រាក់ទាក់សំណេះសំណាលគ្នាចុះ ព្រោះយើងមានកិច្ចការរបស់យើង គឺប្រញាប់ដើរសំដៅចូលក្នុងជំរំ ដើម្បីផ្តិតយករូបភាព និងជួបសម្ភាសន៍ជាមួយជនភៀសសឹក ។ មិត្តអ្នកអានជាទីគោរព! ក្នុងនាមជាអ្នកកាសែតផង និងជាតំណាងពលរដ្ឋម្ចាស់អំណោយក្នុងសហគមន៍ខ្មែរហ្វីឡាដែលហ្មេ្លផង គឺពិតជាមានការឡើយហត់ក្នុងកិច្ចការខ្លាំងណាស់ តែយើងគ្មានទេពាក្យថារុញរា ហើយផ្ទុយទៅវិញគឺពេញចិត្តពេញថ្លើមចំពោះកិច្ចការមនុស្សបែបនេះណាស់ ។

បន្ទាប់ពីចំណាយវេលាជិតមួយម៉ោងក្នុងជំរំទើបយើងត្រឡប់មកកាន់ក្រុមការងារ និងអាជ្ញាធរមូលដ្ឋានដែលកំពុងនិយាយគ្នាពីរឿងកិច្ចការអ្វីម្យ៉ាង ដែលយើងមិនបានដឹងនៅជិតក្លោងទ្វារចូលវត្ត ។ ពេលមកដល់យើងមានការខកចិត្តបន្តិចដែរ ព្រោះលោក ស៊ូ អេងឡេង បានប្រាប់យើងថា "គេមិនទាន់ឱ្យពួកយើងចែកអំណោយឥឡូវនេះទេ ព្រោះមានខាងកាកបាតក្រហមខ្មែរកំពុងបំពេញបេសកកម្មដំណាលគ្នានេះដែរ តែគេថាចាំដល់ថ្ងៃបន្តិចប្រមាណជាម៉ោង១១ ឬ១២ថ្ងៃត្រង់ទើបបានគេឱ្យពួកយើងចែក..." ។

ដោយការចង់បំពេញភារកិច្ចមនុស្សធម៌ឱ្យបានចប់ចុងចប់ដើម ទើបយើងគ្មានប្រតិកម្មឬទោមនស្សចំពោះបទបញ្ជារបស់អាជ្ញាធរ និងពីសំណាក់សមត្ថកិច្ចឡើយ ហើយយើងក៏បានធ្វើដំណើរទៅកាន់ទីរួមខេត្តតាមរយៈការធ្វើអន្តរាគមន៍ និងជូនដំណើរដោយលោក សុង ដើម្បីឆ្ពោះទៅកាន់ទីជម្រករបស់ជនភៀសសឹកដទៃៗជាច្រើនក្រុមផ្សេងទៀត ដែលបានបោះតង់នៅតាមទីវត្តអារាមនានា និងនៅតាមបរិវេណនៃសាលាបឋមសិក្សាជាច្រើនកន្លែងដែលយើងពុំអាចចាំអស់ ។ ដូចការអះអាងរបស់លោក សុង មែននៅទីនោះ យើងឃើញនូវទិដ្ឋភាពដ៏សង្វេកនៃជនភៀសសឹក ពួកគាត់សំដៅចោមរោមក្រុមការងារយើង.ពួកគាត់អង្វរយ៉ាងទន្ទឹងមករកយើងថា "សុំអង្គរមួយការុងមក ខ្ញុំដាច់ពោះហើយ...!" ហើយ ពាក្យអង្វរបែបនេះត្រូវបានបន្លឺស្ទើរគ្រប់ៗគ្នាក្នុងខណៈដែលយើងកំពុងជួបរវល់ជាមួយនឹងម៉ាស៊ីនថត ដើម្បីសម្រិតសម្រាំងផ្តិតយករូបភាពដ៏កម្រនៅទីនោះ ។

ទាក់ទងនឹងការអង្វរករបស់ជនភៀសសឹកនៅទីនោះ យើងបានដាក់ជាសំណួរដល់ពួកគាត់ថា "តើធ្លាប់មានអង្គការឬក្រុមណាធ្លាប់បានចុះមកជួយផ្តល់ស្បៀងអាហារដល់បងប្អូនដែរឬទេ?" ។ ភ្លាមៗនោះពួកគាត់ឆ្លើយម្តងម្នាក់ដោយទឹកមុខស្រពាប់ស្រពោនថា "មិនធ្លាប់មានខាងណាមកជួយឡើយតែខាងកាកបាទក្រហមធ្លាប់ចុះមកម្តងម្កាលដែរ ។ តែពុំមានចែកអំណោយអ្វីឡើយ គឺគ្រាន់តែឱ្យកាត(Card)ក្នុងមួយគ្រួសារមួយសន្លឹកសម្រាប់ចាំចែកអំណោយតែរហូតមកទល់ពេលនេះកាតនោះយើងកាន់ស្ទើរតែរលួយអស់ទៅហើយ គឺនៅពុំទាន់មានគេមកចែកឱ្យទៀត" ។

ជាការពិតយើងទទួលស្គាល់ និងសារភាពដោយត្រង់ថា យើងមានការរារែក និងអល់អែកយ៉ាងខ្លាំងចំពោះការទទួចអង្វរពីសំណាក់បងប្អូនជនភៀសសឹកនៅទីនោះព្រោះ"របស់តិច.មនុស្សច្រើន"ដូច្នេះយើងក៏សម្រេចឱ្យតំណាងម្នាក់ជាអ្នកជ្រើសរើសរកគ្រួសារណាដែលក្រខ្សត់ខ្លាំងជាងគេ ទើបយើងជូនស្បៀងដល់ពួកគាត់តាមរយៈតំណាងម្នាកជាអ្នកចែកផ្ទាល់ហើយយើងប្រញាប់បន្តដំណើរទៅកាន់កន្លែងផ្សេងទៀត តាមការណែនាំរបស់លោក សុង ដែលជាម្ចាស់ស្រុកនៃទឹកដីជាប់ភ្នំដងរែកមួយនេះ ។ មិនបង្អែរបង្អង់យូរយើងក៏ប្រញាប់បត់រថយន្តត្រឡប់ទៅកាន់វត្ត"ចូកគ្រួស" វិញ ព្រោះជិតដល់ម៉ោងកំណត់ហើយយើងស្រេកឃ្លានក្នុងការចែកទាន

(តទៅទំព័រទី១៧)

ANGKOR AUTO SERVICE,INC.

ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

Auto Body and Maintenance

BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវិយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អ៊ីនសួរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

ហាងខ្ញុំរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

Rathe's Auto Service

State and Emission
Inspaction General
Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY

- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកិរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ឌពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងទូរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

តមកពីទំព័រ ១៦

បែសកម្មមនុស្សធម៌ដ៏ចម្រូង...

យើងចង់ឃើញជនភៀសសឹកទទួលអំណោយដោយផ្ទាល់ភ្នែក និងចង់ចែកដោយផ្ទាល់ដៃ ប៉ុន្តែពេលទៅដល់វត្ត "ចូកគ្រួស" តាមការកំណត់នោះ ត្រូវបានអាជ្ញាធរមូលដ្ឋានលេបសំដីជាលើកទី២ ម្តង ដែលជាហេតុធ្វើឱ្យក្រុមការងារមនុស្សធម៌យើងមានការខកចិត្តសោកស្តាយលាយឡំនិងការខឹងសម្បារយ៉ាងខ្លាំង ។

ប្រិយមិត្តជាទីរាប់អានចំពោះអ្វីដែលយើងនឹកស្មានមិនដល់យល់មិនជ្រៅនោះ គឺទង្វើររបស់អាជ្ញាធរមូលដ្ឋានដែលបានរារាំងមិនឱ្យក្រុមការងារយើងចែកអំណោយឡើយ ក្នុងខណៈដែលជនភៀសសឹកជាច្រើនពាន់គ្រួសារកំពុងតែចាំទទួលអំណោយដោយតក់ក្រហល់នោះ.ទង្វើរដ៏ចម្លែកខុសពីប្រក្រតីបែបនេះ ត្រូវបានទទួលរងនូវការស្តីបន្ទោសយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋដែលជាជនភៀសសឹក ។ ដោយការមិនអស់ចិត្តយើងបានសុំសម្ភាសន៍ជាមួយចៅសង្កាត់ម្នាក់ដែលអះអាងថា ជាអ្នកមើលការខុសត្រូវ និងទទួលបន្ទុកលើជនភៀសសឹកទាំងឡាយក្នុង"វត្តចូលគ្រួស" អំពីមូលហេតុនៃការបដិសេធដមិនព្រមទទួលយកអំណោយពីសប្បុរសជន។ ចំពោះចម្លើយដ៏មិនសមហេតុសមផលរបស់ចៅសង្កាត់ដែលឆ្លើយយកៗចូចខ្លួនបានធ្វើឱ្យយើងចង់ខឹងបន្តិចចង់សើចហួចចិត្តបន្តិច ព្រោះគាត់បានអះអាងថា "នេះជាបញ្ជាចេញពីថ្នាក់លើ"។ មែនទែនទៅតាមការប៉ាន់ស្មានរបស់យើងនេះប្រហែលជាបទបញ្ជាដាច់ខាតចេញពីថ្នាក់លើពិតប្រាកដហើយមើលទៅ ។ រីឯលោកចៅសង្កាត់រូបនោះក៏ពិបាកនឹងឆ្លើយចំពោះសំណួររបស់យើងណាស់ដែរ ។ លោកបានថ្លែងនៅចំពោះមុខជនភៀសសឹកក្នុងខណៈដែលយើងកំពុងតម្រង់ម៉ាស៊ីនថតវីដេអូ (Camara Recorder) ទៅរកគាត់យ៉ាងដូច្នេះថា " ខ្ញុំក៏សោកស្តាយខ្លាំងណាស់ដែរ តែធ្វើម៉េចនេះ ជាបញ្ជាហើយខ្ញុំយល់ណាស់ថា បងប្អូនចង់បានអំណោយពីអស់លោកយ៉ាងប្រាកដ ហើយខាងអស់លោកក៏ចង់ចែកអំណោយដល់បងប្អូនយើងនៅទីនេះដែរ..."

ដោយស្ថាការណ៍ហាក់មិនធូរស្រាល និងមិនអំណោយផលសម្រាប់ក្រុមការងារសប្បុរធម៌យើងទើបតម្រូវឱ្យមានការពិភាក្សាគ្នាយ៉ាងល្បឿនមួយអំពីយន្តការនៃការចែកអំណោយជាបន្តទៀតតើយើងត្រូវធ្វើយ៉ាងម៉េចបើពេលនេះត្រូវគេមិនឱ្យយើងចែក ? ហើយយើងក៏មិនអាចនៅបង្អែបង្អង់ក្នុងជំរំនៃវត្តចូកគ្រួសយូរទៀតដែរ ព្រោះកម្លាំងប៉ូលិស ប៉ៃអឹម និងទាហាន ត្រូវបានគេបញ្ជូនមកកាន់វត្តមួយនេះភ្លាម១ដែរ ដែលមើលទៅហាក់ដូចជាចម្លែកខ្លាំងណាស់ ។

ដោយមានការអាក់ស្រពន់ចិត្តលាយឡំនឹងការខឹងសម្បារចំពោះអាជ្ញាធរមូលដ្ឋានផងនោះលោក ស៊ូ អេងឡេង បានរកដំណោះស្រាយយ៉ាងងាយស្រួលថា"បើគេមិនឱ្យយើងចែកហើយមានតែទៅដូរអង្ករយក លុយត្រឡប់ទៅភ្នំពេញវិញចាំគិតគ្នារឿងចែកអំណោយតាមរបៀបផ្សេងថ្ងៃក្រោយទៀត..." ។ យើងក៏មិនជំទាស់នឹងដំណោះស្រាយនេះឡើយ ប៉ុន្តែអង្ករដែលនៅសល់ប្រមាណជា៧០ភាគរយនោះ គឺយើងដូរយកលុយតែពាក់កណ្តាលបានហើយ ទុលពាក់កណ្តាលទៀតសម្រាប់ចែកតាមផ្លូវ! ។នេះជាសំណូមពរដែលយើងចង់បាន ហើយក្រុមការងារទាំងអស់ក៏បានឯកភាព ។ មិនបង្អង់យូរយើងក៏ប្រញាប់ធ្វើដំណើរទៅកាន់រោងម៉ាស៊ីនកិនស្រូវ "អេង សួរ" ដែលនៅមិនឆ្ងាយពីវត្តចូកគ្រួសប៉ុន្មានឡើយ ដើម្បីសុំដូរយកលុយពាក់កណ្តាលវិញ ។ ទីបំផុតម្ចាស់រោងម៉ាស៊ីនក៏យល់ព្រមចំពោះអ្វី ដែលពួកយើងស្នើសុំបន្ទាប់ពីបានអធិប្បាយប្រាប់រឿង ហេតុនៅក្នុងវត្តចូកគ្រួសដល់គាត់ហើយនោះ ប៉ុន្តែតម្លៃអង្ករត្រូវខាតចំនួន៦០ដុល្លារ ថ្លៃកម្លាំងពលកម្ម ហើយ លុយដែលបានមកវិញនោះ គឺលោក អេងឡេង ជាអ្នកទុកដាក់ ។

អាកាសធាតុកាន់តែក្តៅ ពេលវេលាកាន់ទែរកិលទៅមុខជាលំដាប់ដូច្នេះយើងចាំបាច់ត្រូវតែ

ប្រញាប់ធ្វើដំណើរត្រឡប់ថយក្រោយ គឺឆ្ពោះទៅកាន់ខេត្តស្បើមរាប និងភ្នំពេញជាបន្ទាន់ ។ រថយន្តក៏បានមកដល់ក្លោងទ្វារនៃវត្តចូកគ្រួសជាថ្មី ។ យើងក៏ប្រាប់អ្នកបើកបរឱ្យឈប់មួយភ្លែតហើយចុះពីរថយន្តចូលទៅក្នុងវត្តចូកគ្រួសព្រោះមិនអស់ចិត្តនឹងទង្វើររបស់"ថ្នាក់លើ"ដែលមិនគួររារាំងមិនឱ្យក្រុមការងារយើងចែកអំណោយមនុស្សធមិដល់ជនរួមឈាមជាខ្មែរដូចគ្នាឡើយ ហើយចំពោះអ្វីដែលយើងធ្វើនេះ គឺក្នុងនាមមនុស្សធមិយ៉ាងពិតប្រាកដពោលគឺមិនពាក់ព័ន្ធ ឬយកឈ្នោះគណបក្សនយោបាយណាមួយមកឡូកឡំឡើយ ។

ក្នុងខណៈដែលយើងដើរចូលទៅកាន់វត្តចូកគ្រួសនេះត្រូវបានបុរសម្នាក់ដែលគេដឹងថាជាមន្ត្រីរាជការថ្នាក់ខេត្តផងនោះ បានប្រាប់យើងដោយប្រុងប្រយ័ត្នថា "បើចង់ឱ្យប្រជាពលរដ្ឋនៅទីនេះបានទទួលអំណោយលុះត្រាតែក្រុមរបស់លោកប្រគល់របស់ទាំងនោះទៅឱ្យកាកបាទក្រហមកម្ពុជា ឬក៏ទៅឱ្យមូលនិធិបាយ័ន្តជាមុនរទើបអាចទៅរួច បើមិនដូច្នេះទេក្រុមរបស់លោកក៏អាចប្រគល់អំណោយទាំងនោះឱ្យទៅគណៈកម្មការនៃវត្តចូកគ្រួសក៏បានដែរ ចាំពួកយើងចាត់ចែងចែកឱ្យប្រជាពលរដ្ឋដោយខ្លួនឯង ពុំចាំបាច់ពិបាកដល់ពួកលោកឡើយ... ។ប្រិយមិត្រអ្នកអាចព្រមទាំងសប្បុរជនជាទីរាប់អាន ! សូមជួយពិចារណាផងចុះតើសមហេតុផលដែរឬទេ ។ បងប្អូនខ្មែរនៅឯទីក្រុងហ៊ីឡាដែលហ្សៀខំធ្វើបុណ្យដើម្បីប្រមូលបច្ច័យយកមកជួយខ្មែរគ្នាឯង ។ តែត្រូវគេហាមមិនឱ្យចែកបើឱ្យចែកលុះត្រាតែផ្ទេរ របស់ទាំងនោះទៅឱ្យកាកបាទក្រហមកម្ពុជា ដែលមានអ្នកស្រី ប៊ុន រ៉ានី ប្រពន្ធលោក ហ៊ុន សែន ជាប្រធានឬក៏មូលនិធិបាយ័ន្តរបស់ទូរទស្សន៍បាយ័ន្តដែលមាន ហ៊ុន វណ្ណា កូនស្រីបង្កើតរបស់លោក ហ៊ុន សែន នាយិការ ។ តើយើងល្ងង់ខ្លៅព្រមផ្ទេរអំណោយទាំងនោះ ទៅឱ្យក្រុមទាំងពីរដូចបានរៀបរាប់ខាងលើដែរឬទេ? ចម្លើយពិតជាពុំអាចទៅរួចឡើយ ព្រោះអង្ករបានក្លាយ ទៅបាយរួចទៅហើយ បើចង់បានអំណោយទៅឱ្យកាកបាទក្រហម ឬមូលនិធិបាយ័ន្ត គឺរង់ចាំទទួលពីក្រុមផ្សេងទៀតចុះអស់លោកអើយ ព្រោះយើងមានចង់បានប័ណ្ណសរសើរពីអស់លោកថ្នាក់លើទាំងនោះឡើយ។ មិនបង្អង់យូរទៀតឡើយ យើងក៏ប្រញាប់ឡើងរថយន្តឆ្ពោះទៅកាន់ខេត្តស្បើមរាបព្រោះថ្ងៃកាន់តែរសៀលជ្រៀសជ្រេរទៅហើយ ក្រែងយប់ជ្រុលត្រឡប់ទៅភ្នំពេញវិញពុំកើត ។ នៅតាមផ្លូវដែលយើងកំពុងធ្វើដំណើរពីស្រុកសំរោងឆ្ពោះទៅកាន់ខេត្តស្បើមរាបយើងសង្កេតឃើញជនភៀសសឹកធ្វើដំណើរតាមគោយន្តជាហ្វូងហែរឆ្ពោះទៅកាន់លំនៅដ្ឋានរៀង១ខ្លួនវិញបន្ទាប់ពីស្ថានការណ៍នៅតាមព្រំប្រទល់មានលក្ខណៈធូរស្រាល។ ដូច្នេះនេះជាឱកាសដ៏សមរម្យមួយសម្រាប់យើងក្នុងការកាត់គោយន្តឱ្យឈប់ ហើយផ្តល់អំណោយដល់ពួកគាត់ ។ មិត្តអ្នកអានជាទីមេត្រី ! តើទង្វើរបស់យើងជាការខុស និងបទបញ្ជារបស់ថ្នាក់លើដែរ ឬទេ ? គេហាមមិនឱ្យចែកអំណោយនៅក្នុងជំរំតែយើងនៅតែគឃ្លើនកាក់គោយន្តរបស់បងប្អូនជនភៀសសឹកដែលកំពុងធ្វើដំណើរ ដឹកកូនដឹកចៅចានឆ្នាំងសំពឹងសំពោងហើយជូនអង្ករ ដល់ពួកគាត់ក្នុងមួយគោយន្ត១អង្ករមួយការ៉ុងបែបនេះ ? តាមមើលទៅប្រហែលជាមិនខុសទេដឹង ? ព្រោះគេបានហាមតែនៅក្នុងជំរំទេតើ!ប៉ុន្តែគេពុំបានហាមយើងមិនផ្តឱ្យចែកតាមផ្លូវឯណា ? ហើយយើងបន្តធ្វើសកម្មភាពបែបនេះរហូតទាល់តែអស់អង្ករដែលនៅសេសសល់ទាំងប៉ុន្មាននោះ ។

រឿងរ៉ាវនៅឯវត្ត"ចូកគ្រួស"យើងពុំទាន់ស្ងប់ចិត្តត្រឹមហ្មឹងឡើយ ហើយដោយសារតែយើងធ្លាប់ធ្វើជាអ្នកកាសែតកំប៊ិចកំប៉ុកមួយកាលពីនៅស្រុកខ្មែរជិត១០ឆ្នាំមុនដែរ ទើបធ្វើឱ្យយើងនៅមានទំនាក់ទំនងនិងនៅមានមិត្តភក្តិជាអ្នកព័ត៌មានជាច្រើនអង្គភាពដែរ ។ ដូច្នេះ យើងបានស្ទុះស្ទែងហៅទូរស័ព្ទទៅកាន់អ្នកកាសែតនានា ដើម្បីឱ្យបានដឹងអំពីព័តិមានដ៏ចម្លែកនៅឯវត្ត "ចូកគ្រួសនេះ"ប៉ុន្តែមានអ្នកកាសែតមួយចំនួនថា "ម៉ែចបានជាលោកឯងមិនប្រគល់អំណោយទាំងហ្នឹងទៅឱ្យកាកបាទក្រហមកម្ពុជា ឬក៏មូលនិធិបាយ័ន្តនោះវាចប់រឿងហើយ...!" ។គ្រាន់តែឮនូវអនុសាសន៍ល្ងីល្ងើបែប ហ្នឹងយើងពុំបានសន្ទនាយូរទៀតឡើយ ព្រោះខ្លាចអស់មីនុតទូរស័ព្ទ ដោយសារទូរស័ព្ទមានទឹកប្រាក់ពុំសូវគ្រប់គ្រាន់និងមានកំណត់ ។ ប៉ុន្តែចំពោះអ្វីដែលធ្វើឱ្យយើងស្ងប់ចិត្ត គឺព្រឹកឡើងត្រូវបានវិទ្យុផ្សាយជាភាសាខ្មែរចំនួនពីរនឹងមានស្នាក់ការក្នុងសហរដ្ឋអាមេរិក ព្រមទាំងកាសែតក្នុងស្រុកមួយចំនួនបានចុះផ្សាយនូវព័តិមាននោះយ៉ាងល្បឿនបំផុតផងដែរ ។

យើងសូមបញ្ជាក់រឿងចែកអំណោយនៅឯខេត្តឧត្តរមានជ័យត្រឹមហ្នឹងសិនចុះហើយយើងបែរមកនិយាយរឿងលុយនៅសល់(១៣៥២ដុល្លារ) វិញម្តង ។ សូមជម្រាបថា ពាក់កណ្តាលនៃចំនួនលុយដែលនៅសល់នោះ(៦០ភាគរយដុល្លារ) គឺយើងសម្រេចផ្ទេរជូនដល់មូលនិធិ"ករុណាសង្គ្រោះ" របស់លោក ស៊ូ អេងឡេង ចំណែកឯពាក់កណ្តាលទៀត គឺ៦០ភាគរយដុល្លារ ត្រូវយើងធ្វើជាទានដល់ជនទីទ័លក្រ កុមារកំព្រា អ្នកកើតអេដស៍ ចាស់ជរាគ្មានទីពឹងនាក់ ជនពិកា ក្មេងរើសអេតចាយ និងជូនជី តាជី ដែលស្នាក់នៅក្នុងវត្តដែលមានលក្ខណៈអត្តខាតខ្លាំង... ។ក្រៅពីនោះថវិកាមួយចំនួនត្រូវបានយើងសហការណ៍ជាមួយមូលនិធិ"ករុណាសង្គ្រោះ"ដោយការចុះដល់មូលដ្ឋានផ្ទាល់ក្រុមការងាររបស់លោក អេងឡេង ។

ជាអវសាន្តសូមផ្ញើនិសង្សកើតមានដល់សប្បុរសជនទាំងឡាយដែលបានចូលរួម ចាប់មគ្គផលជួយដល់បងប្អូនខ្មែរនៅឯប្រទេសកំណើររបស់យើងនិងជូនពរ ឱ្យមានសេរីសួរស្តី សុភង្គលល្អក្នុងគ្រួសារ និងរកទទួលទានមានបានគ្រប់ៗគ្នា ។

អត្ថបទនេះនិពន្ធដោយខ្ញុំបាទ អឹម ល្បើម ជាស្មេរ របស់កាសែតខ្មែរប៉ុស្តិ៍និងជាតំណាងឱ្យប្រជាពលរដ្ឋម្ចាស់អំណោយក្នុងសហគមន៍ខ្មែរនាទីក្រុងហ៊ីឡាដែលហ្សៀដែលបានចុះផ្ទាល់ដល់ដំរំជនភៀសសឹកខ្មែរ ជាច្រើនកន្លែងនៅឯខេត្តបន្ទាយមានជ័យ ។ រូបភាពជាច្រើនទាក់ទងនឹងសកម្មភាពចែកអំណោយ លោកអ្នកអាចចូលទៅកាន់ (Face Book Tony chhoum) ។

ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

ប្រែសម្រួលដោយ : តឹម រៃមល

(**តពីលេខមុន**)

លោកប្រធានចម្រុះផ្នែកបារាំងបញ្ជាក់ថា "សមាគមអន្តរជាតិ ពុំអាចស្ថិតលើវាសនាកម្ពុជារហូតនោះទេ" ប្រសិនជាភាគីខ្មែរ ពុំមានឆន្ទៈផ្នែកនយោបាយឱ្យបានទៅដល់ទីបញ្ចប់"។ ត្រីភាគីកម្ពុជាបានបង្ហាញចេតនា១០០ភាគរយគាំទ្រគម្រោងរបស់ក្រុមសមាជិកអចិន្ត្រៃយ៍ (P-5)។ រដ្ឋកម្ពុជានៅស្ងាក់ស្ងើរ ។ សេចក្តីប្រកាសមួយក្រៅផ្លូវការដោយ វ៉ាហ្វឺតឌឺន អាម៉ាត់ ។ បើសិនជាការព្រមព្រៀងបានមកដល់នុះ សំនួរទាំងឡាយដែលនៅសល់នឹងត្រូវទុកជាការចរចារស៊ីជម្រៅមួយ ។ ហ៊ុន សែន ទទួលបញ្ហាសុខភាពនាពេលប្រជុំ ។

៤មករា១៩៩១ : ស្តេចសីហនុ មានបន្ទូលថា ទ្រង់ពុំស្ថិតក្នុងបក្សនយោបាយណាមួយទេ។ ក៏ប៉ុន្តែស្តេចនៅតែជាប្រធានរដ្ឋាភិបាលជាតិកម្ពុជា។

៥មករា : រដ្ឋាភិបាលរដ្ឋកម្ពុជាពុំអាចមានទំនុកចិត្តចុះសម្រុងជាមួយខ្មែរក្រហមទេ នាឱកាសដំណើរការបណ្តោះអាសន្ននេះ ។ រដ្ឋកម្ពុជារឹងធ្ងឹងពុំព្រមប្តូរដំណើរការរដ្ឋាភិបាលនឹងកងពលយោធារបស់ខ្លួនទេ។

៦មករា : តុលាការយុត្តិធម៌នៅទីក្រុងបារីសទទួលបណ្តឹងចោទប្រកាន់ស្តេច សីហនុ ដែលត្រូវបានដាក់បណ្តឹងដោយលោក ហោ ណាំហុង : "ស្តេច សីហនុ ពុំអាចនៅតែប្រកាន់តួនាទីខ្លួនជាប្រធានរដ្ឋទៀតបានទេ ឬក៏អភ័យឯកសិទ្ធិផ្លូវទូតណាមួយបានឡើយ"។ ស្តេច សីហនុ ត្រូវបានផ្តន្ទាទោស។

១២កុម្ភៈ : រដ្ឋកម្ពុជាធ្វើការផ្លាស់ប្តូរតំណាងខ្លួន ក្នុងបរិបទឧត្តមប្រឹក្សាសន្តិសុខ (CNS)។

១៣-២៤កុម្ភៈ : លោក យូគីយោ អ៊ីម៉ាហ្កាយ៉ា អ្នកការទូតជាតិជប៉ុនដែលជាអ្នកជំនាញបញ្ហាខ្មែរមកដល់ក្រុងភ្នំពេញ។

២៣កុម្ភៈ : រដ្ឋប្រហារយោធានៅក្រុងបាងកក។ មេទ័ព សុ ជីនដា និយាយថា: "បើរកអ្នកចង់ដោះស្រាយបញ្ហាទាំងឡាយត្រូវតែអនុញ្ញាតឱ្យខ្មែរក្រហមមានចំណែកក្នុងអំណាច"។

២៨កុម្ភៈ : សភារដ្ឋកម្ពុជាបានបោះឆ្នោតប្រឆាំងគម្រោងរបស់សមាជិកអចិន្ត្រៃយ៍ P-៥ ដោយបង្ហាញការមិនទុកចិត្តលើគម្រោងនេះ :

១. កុំឱ្យមានគម្រោងពាក់ព័ន្ធលើការសម្លាប់ប្រល័យពូជសាស្ត្រ? ក្នុងការទប់ស្កាត់ ការត្រឡប់មកវិញនូវរបប ប៉ុល ពត។

២. ស្ថានភាព ស្តាតនុយកូ (Stateu-go) ត្រូវបានកែរតម្រង់ឡើងវិញ នៅមុនការបោះឆ្នោត។

៥មិនា : ដោយពុំទាន់មានភាពស្និទ្ធិស្នាល រវាងភាគីជម្ពោះខ្មែរទាំងបួនទស្សនកិច្ចរបស់ក្រុមប្រធានចម្រុះនៃកិច្ចព្រមព្រៀងត្រូវបានពេលក្រោយ។

៧មិនា : រដ្ឋមន្ត្រីមាននៃអូស្ត្រាលី បានថ្លែងសេចក្តីតក់ក្រហល់នៅចំពោះមុខកិច្ចចរចារវាងភាគីជម្ពោះខ្មែរ ។ **(នៅមានតលេខក្រោយ)**

TWIN PHOENIX

銘盛

ហាង្រស្សង

Opening Hours
Mon. - Sat. : 10 am - 6 pm
Sunday : 10 am - 4:30 pm

TWIN PHOENIX INC.

Custom Jewelry Sales & Repairs
24K-18k-14k-10k-silver-diamonds-watches
40+ years of experience in Repairing all Type of Watches by most advanced technology
Authentic Watches Dealer has over 3,000 Watches in Stock!
Widest range of collections, grandfather clocks – watches – pocket watches – clocks – antiques – cross pens – zippo lighters – watch bands – engraving.
6429 Woodland Ave., Phila., PA 19142
Phone/Fax: 215-727-9542
www.twinphoenix.net

ហាង មាស ពេជ្រ នាឡិកា ទិញ លក់ ជួសជុល

ត្រូវការលក់ហាង និងផ្ទះ

ម្ចាស់ធើទៅនៅរដ្ឋផ្សេង ,មានផ្ទះពីរ និងហាងមួយនៅក្នុងតំបន់សហគមន៍ខ្មែរ ដែលត្រូវលក់ចេញអាចទិញតែហាង ឬ Building

Business & Properties For Sale
2224 S. 7th St. Philadelphia, PA 19148
Checking Cashing, Lottery, Pay Bills, Western Union, Cigarette, Prepaid & Pinless Phone-card, Services, Phone Accessory, Faxing, Copying, Lamination Services

Two Home Properties in South Philly: Jackson & 7th St.; 16th & Morris.

ទាក់ទងមក ផល Contact Paul at 215-668-6061

ពុទ្ធប្បវត្តិអមដោយរូបភាព

A Pictorrial Biography of Saky amuni Buddha

- រូបភាព និងរឿងដើមជាភាសាថៃ ដោយ គុណាប៉ាយុតា
- បកប្រែជាភាសាអង់គ្លេស ដោយ ហ្សឺត .អេ.លឺ
- ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី
- បកប្រែជាភាសាខ្មែរដោយភិក្ខុ គង់ អាំ

- Original Illuatration and Naration in Thai by Gunapayuta.
- Translation into English by A Lu.
- Coloring by Yann Fang Lee
- Translation into Khmer by Bhikkhu Kong Am.



(Continued to After Issue)

134- After the Buddha had sent out, for the first time, sixty of his arhant disciples to preach at various places, he left Mrgadava and journeyed toward Mag-adha in the south-east and finally arrived at Uruvilva village. He took up residence at the place of the knot-hair cult, a group of a thousand people, the leaders of whom were the three Kasyapa brothers. In order to break through their wrong views completely, the Buddha expounded to their leaders, basic Buddha-dharma which he had recently realized. After hearing the Buddha´s sermon, they all were full of joy and made a request to leave home to become Buddhist monks. The three Kasyapa brothers and the thousand followers all became arhants later.



135- Then the Buddha took his arhants disciples and went to Rajagrha to fullfill his promise to King Bimbisara to teach and enlighten the people of Magadha. Upon arriving at Rajagrha, Bud-dha and his disciples resided at Palm Garden; and with a fully compassionate heart, he preached in various ways to cause King Bimpisara and his people to comprehend and they expressed their own wish to be the Buddha´s disciples.

136- King Bimpisara told the Buddha that when he was a crown prince, he had the wish that besides being a king he would also someday, be the first among all kings to hear teaching of th Buddha, who had attained the supreme enlightenment. Now all his wishes had been realized, and so he decided to take refuge in the **Buddha**, the **Dharma** and the **Sangha** and formally become a grhapati (i.e, a Buddhist follower at home). Later he offered to donate **Venuvana,** a park in a bamboo grove, the the Buddha as a residence for the bhiksus. Hence **Venuvana** became the earliest monastery in Buddhist history.



137- One morning, on his way from Venuvana to Rajagrha to accept his daily ration of food, the Buddha encountered a youth who was wet through and through, looking as if he had just emerged from the water. The young man stood in the middle of the road and bowed one after the order to the east, south, west and north; then he raised his head and saluted heaven, and at the last, knelt down and saluted the earth. Then he cast grain in all the directions he had saluted.

1384- បន្ទាប់ពីព្រះបរមគ្រូទ្រង់បានបញ្ជូនព្រះអរហន្តសាវ័កទាំង៦០អង្គ ទៅសំដែងធម៌នៅតាមស្រុកតូចធំនិគមរាជធានីផ្សេងៗរួចហើយ. ព្រះអង្គក៏យាងចេញពីព្រៃមិគទាយវនទិមន្តឆ្ពោះទៅនគរមគធៈបែកខាងទិសនិរតី បានទៅដល់ភូមិមួយឈ្មោះឧរុវេលា។ ព្រះអង្គបានគង់នៅត្រង់កន្លែងអ្នកកាន់ប្រពៃណីបូងសក់ (ព្រាហ្មណ៍) ជាក្រុមមួយដែលមានមនុស្ស១ពាន់នាក់. គ្រូនៃព្រាហ្មណ៍ទាំងនោះគឺ **កស្សបៈ** ទាំង៣ដែលជាបងប្អូននឹងគ្នា។ ដើម្បីបំបាក់នូវទិដ្ឋិយល់ខុសរបស់ព្រាហ្មណ៍ទាំងឡាយឱ្យបាក់ខ្ទេចខ្ទី. ព្រះវិជិតមារជាម្ចាស់ទ្រង់សំដែងធម៌ទាន្យល់ដល់ជនជាគ្រូរបស់ព្រាហ្មណ៍ទាំងនោះនូវគោលធម៌ ដែលព្រះអង្គទើបនឹងត្រាស់ដឹងថ្មី។ ក្រោយពីបានស្តាប់ព្រះធម៌ទេសនារបស់ព្រះអង្គចប់ជនទាំងឡាយមានចិត្តពេញទៅដោយបីតិសប្បាយរីករាយ ហើយបានក្រាបថ្វាយបង្គំទូលសុំបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនា។ មិនយូរប៉ុន្មាន. កស្សបៈទាំង៣ និងសិស្សទាំង១ពាន់នាក់ ក៏បានសំរេចធម៌ជាព្រះអរហន្តទាំងអស់អង្គ។

1385- បន្ទាប់មក ព្រះបរមសាស្តាទ្រង់នាំព្រះអរហន្តទាំងអស់ទិមន្តទៅកាន់នគរាជគ្រឹះ ដើម្បីបំពេញតាមការសន្យារបស់ព្រះអង្គថ្វាយព្រះបាទពិម្ពិសារ ដើម្បីបង្រៀនជនទាំងឡាយក្នុងដែនមគធៈឱ្យបានយល់ដឹងព្រះធម៌។ កាលបើបានដល់នគរាជគ្រឹះហើយ. ព្រះពុទ្ធព្រមទាំងសាវ័កទាំងអស់ទ្រង់គង់នៅក្នុងសួនតាលវ័ន (ព្រៃត្នោត) ដោយព្រះទ័យពោរពេញទៅដោយព្រះមហាករុណា. ព្រះអង្គទ្រង់សំដែងព្រះធម៌តាមវប្បៈផ្សេងៗជាច្រើន ធ្វើឱ្យព្រះបាទពិម្ពិសារ និងប្រជារាស្ត្រព្រះអង្គបានយល់ដឹងនូវធម៌និងចូលចិត្តគ្រប់ៗគ្នា ហើយជនទាំងឡាយបានប្រគល់ថ្វាយខ្លួនសុំធ្វើជាបរិស័ទរបស់ព្រះអង្គ។

1386- ព្រះបាទពិម្ពិសាររាជទ្រង់ធ្លាប់បានទូលព្រះពុទ្ធជាម្ចាស់ថា កាលពីព្រះអង្គនៅជារាជ្ជទាយាទ ទ្រង់បានធ្វើសេចក្តីប្រាថ្នាថា ក្រៅពីហ៊ាន:ជាព្រះមហាក្សត្រ នៅថ្ងៃណាមួយខាងមុខ សូមឱ្យព្រះអង្គបានជាអ្នកទីមួយក្នុងចំណោមមហាក្សត្រទាំងឡាយ ដែលនឹងបានស្តាប់ធម៌របស់ព្រះពុទ្ធ ជាបុគ្គលបានត្រាស់ដឹងនូវធម៌ដ៏ប្រសើរបំផុតនេះ។ ពេលនេះ រាល់សេចក្តីបំណងរបស់ព្រះអង្គបានសំរេចដូចប្រាថ្នា. ដូច្នេះព្រះអង្គទ្រង់ក៏ សំរេចព្រះទ័យយកព្រះពុទ្ធ ព្រះធម៌និងព្រះសង្ឃជាទីពឹងទីរលឹក ហើយក៏ដល់នូវភាពជាគហបតីមួយរូប (គឺជាពុទ្ធសាសនិកមួយរូប ដែលមានការគ្រប់គ្រងផ្ទះ)។ ក្រោយមកទៀត ព្រះមហារាជបានថ្វាយដីឧទ្យានមួយកន្លែងឈ្មោះ **វេឌ្ឍុវ័ន**. ជាឧទ្យានព្រៃឫស្សី. ដល់ព្រះពុទ្ធជាម្ចាស់ដើម្បីធ្វើជាវត្តសំរាប់ភិក្ខុសង្ឃគង់នៅ។ ព្រោះហេតុដូច្នោះ. ឧទ្យានវេឌ្ឍុវ័ន ក៏បានក្លាយជាវត្តមួយមុនគេបង្អស់ក្នុងព្រះពុទ្ធសាសនា។

1387- មានព្រឹកមួយនោះ. ពេលព្រះអង្គកំពុងព្រះដំណើរពីវត្តវេឌ្ឍុវ័ន ទៅក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត្រ. ព្រះបរមគ្រូបានជួបមាណពម្នាក់ដែលខ្លួនគេទាំងមូលទទឹកជោគគ្មានសល់ មើលទៅហាក់ដូចជាគាត់ទើបឡើងមកពីក្នុងទឹក។ មាណពនោះឈរ ចំកណ្តាលផ្លូវ រួចឱនថ្វាយបង្គំគោរពទិសទាំង៤. ខាងកើត. ខាងត្បូង. ខាងលិច និងខាងជើង. បន្ទាប់មក គាត់ងើបងើយក្បាលឡើងលើគោរពសំពះដល់ស្ថានលើ ហើយចុងក្រោយលុតជង្គង់ចុះថ្វាយបង្គំគោរពស្ថានក្រោម។ បន្ទាប់មកទៀតគាត់ក៏បានរោយគ្រាប់ធញ្ញជាតិទៅគ្រប់ទិសទាំងអស់ដែលគាត់បានថ្វាយបង្គំ។ **តទៅលេខក្រោយ**

បុណ្យអុំទូកនៅហ្វីឡាដែលហ្វៀ

រៀបចំដោយវត្តព្រះពុទ្ធរង្សី
ថ្ងៃសៅរ៍ ទី១០ ខែកញ្ញា ឆ្នាំ០១១
នៅផែនទ្បែនឌីង មហាវិថី គូឡុមប៊ីស

The Southeast Asian Dragon Boat Festival

PENN'S LANDING
PHILADELPHIA, PA
SATURDAY, SEPTEMBER 10, 2011
11:00 AM - 5:00PM

EXCITING DRAGON BOAT RACES ♦ FOOD ♦ ASIAN MARKETPLACE ♦ CULTURAL ENTERTAINMENT

contact :
Song Phou 267-978-3379
www. southeastasiandragonboatfestival.org

សូមអញ្ជើញនាំក្រុមគ្រួសារ និងញាតិមិត្តខ្មែរ និងបរទេសមករួមកំសាន្តការប្រណាំងទូក-ភ្លក់ម្ហូបអាហារ -មើលការតាំងលក់វត្ថុអនុស្សាវរីយ៍ ផ្សារអាស៊ី
មានបង្ហាញសិល្បៈវប្បធម៌ និងភ្លេងចម្រៀងខ្មែរ

Sponsored By

PECO
An Exelon Company

Delaware River WATERFRONT Corporation

Presented By

KHMER BUDDHIST HUMANITARIAN ASSOCIATION, INC.

SOUTHEAST ASIAN DRAGON BOAT FESTIVAL COMMITTEE

អាថ៌កំបាំង និងសិល្បៈនៃជីវិត
SECRET AND ART OF LIVING

(តទៅពីលេខមុន)

រៀបរៀងដោយ
លោក ម៉ៅ ច័ន្ទសំណុំ

●●●មេត្តាករុណាការអត់អោនទោសកំហុស និងការដឹងគុណ gratitude សុទ្ធតែជារូបភាពនៃចាមពលវិជ្ជមានដែលមានគុណសម្បត្តិដ៏ឧត្តុង្គឧត្តមដែលអ្នកប្រតិបត្តិសមាធិត្រូវខិតខំបណ្តុះទម្លាប់ឱ្យវិវឌ្ឍធំធាត់ឡើងដើម្បីជាប្រយោជន៍ដល់: **ទី១** ការសំអាតចិត្តមិន Cleansing និង**ទី២** ការបញ្ចូលឱ្យសថ៌ដ៏សក្តិសិទ្ធិនាំមកនូវការជាសះស្បើយជម្ងឺផ្លូវចិត្ត និងជម្ងឺរូបកាយសព្វយ៉ាង Mind and Body healing **ទី៣** ការប្រតិបត្តិសមាធិកាន់តែរីកចំរើន ពីព្រោះធាតុទាំងបីនេះ ជាធាតុផ្ទុយនឹងធាតុបុគ្គល ងៀ ។

-សមាធិមានចរិតបុគ្គលមានន័យថា ដំណើរឈានឡើង និងលទ្ធផលមានទំរង់បែបផែនផ្សេងៗពីបុគ្គលម្នាក់ទៅម្នាក់ៗអាស្រ័យដោយកម្ម ឬទម្រង់ម៉ែម៉ីនៃបុគ្គលម្នាក់ៗនោះមានលក្ខណៈផ្សេងគ្នា ។ ដោយឡែកខ្ញុំផ្ទាល់បានប្រើចំណុចខ្លះនៃមេត្តាភាវនានៅខាងដើមនៃវគ្គសមាធិម្តងៗ ។ ជាក់ស្តែងជួនកាលខ្ញុំលើកយកចំណុចឱ្យការអភ័យទោសឱ្យ ឬឱ្យការផ្សាយមេត្តាឱ្យ ឬឱ្យការសំដែងដឹងគុណឱ្យមកប្រើ ។ អនុវត្តដូច្នេះខ្ញុំពិសោធន៍ឃើញថា ដំណើរសមាធិមានការចាប់ផ្តើមភាពងាយស្រួល ពីព្រោះមេត្តាភាវនាបានធ្វើឱ្យតួបុគ្គល Ego of mind ថមថយចុះ ហើយបើកផ្លូវឱ្យសមាធិឈានឡើងអស្ចារ្យណាស់ !!! ។

២-ការអនុវត្តសមាធិជាក់ស្តែង

ក្រៅអំពីចំណុចលំអិតទ្រឹស្តីខាងលើនេះ ខ្ញុំសូមបន្ថែមចំណុចជាក់ស្តែងមួយចំនួនសំរាប់ជាជំនួយដល់អ្នកដែលមានបំណងចាប់ផ្តើមគិតគូរអំពីសមាធិវិបស្សនានេះ :

២០កន្លែងហាត់រៀន

ដើម្បីចាប់ផ្តើមអនុវត្តសមាធិ គួរអ្នកចំណាយពេល១០ថ្ងៃ ចុះឈ្មោះចូលរៀនសាលាដែលមានគ្រូណែនាំត្រឹមត្រូវនៅមជ្ឈមណ្ឌលនានាលើសកលលោក ។ សូមបើករកអស័យដ្ឋាន ក្នុងគេហទំព័រអិនទឺណែត: Vipassana Meditation taught by S.N. Goenka. មជ្ឈមណ្ឌលបង្រៀនបច្ចេកទេសសមាធិមានត្រប់កន្លែងលើសាកលលោកនៅប្រទេសខ្មែរយើងក៏មានមួយដែរ ។ បើមានបំណងហាត់រៀនសមាធិនៅប្រទេសយើង សូមទាក់ទងទូរស័ព្ទលេខ : (855-012) 689 732 ឬទូរស័ព្ទលេខ (855-012) 488-588 ការចូលរៀននេះ ពុំតម្រូវឱ្យបង់ថ្លៃអ្វីឡើយទាំងកន្លែងស្នាក់នៅទាំងការហូបចុកក្នុងមួយរយៈ ១០ថ្ងៃនេះ ។ ខ្ញុំយល់ថា ការចាប់ផ្តើមហាត់រៀនមានគ្រូ និងមានទីកន្លែងជាការចាំបាច់បំផុត ពីព្រោះការចាប់ផ្តើមដំបូងទាមទារកន្លែងស្ងាត់ជាច់ផុតពីការរស់នៅធម្មតាចំនួន១០ថ្ងៃ តទៅលេខក្រោយ

ភោជនីយដ្ឋាន ណាម វាង (ភ្នំពេញ)
Nam Vang Restaurant

571 Unit#1 Adams Svenue. Philadelphia, PA 19120
(inside Hong Kong Market) (215) 742-9488



ប្រេងរាល់ថ្ងៃលោកអ្នកអាចពិសាចិតត្រឡុកត្រប់សេជាតិផ្លែឈើ ដូចជា:
ទុរេន ឬ អាវ៉ូកាដូ ហើយជាពិសេស
មានចិតអំពៅស្រស់ៗ

១_មុខជំនាញខាងម្ហូបខ្មែរ យ៉ាងចំណាន ដូចជា :
- -គុយទាវភ្នំពេញ
- -គុយទាវ ឬមី-ខគោ
- -ម៉ីកន្ទ្រាំង ឆាសាច់គោ
- -ម៉ីកន្ទ្រាំងឆាគ្រឿងសមុទ្រ
- -បាយឆាគ្រប់មុខ
- -សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ពៅ

២_មុខជំនាញម្ហូបវៀតណាម ល្បីឈ្មោះ ដូចជា :
- -នំបញ្ចុកទឹកត្រីពិសេស
- -នំប៉័ងបាតេ ឬសាច់គោអាំង
- -ខគោ នំប៉័ង ឬ មី និងគុយទាវ
- -បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

Open 7 days a week from 9a.m-9p.m
បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច

ការិយាល័យច្បាប់

ERIK B.JENSEN P.C
A Profesional Corporation

We Handle All INJURY CASES
- Auto/Bus/Train/Motorcycle
- Slip and Fall / Workplace Accidents
- Medical Malpractice
- Nursing Home Neglect
- Dog Bites / Wrongful Death

Criminal Defense – DUI
Adult & Juvenile
Felonies / Misdemeanors / Drug Offenses
Weapons Charges / Murder / Manslaughter
Robbery / Burglary / Theft / Rape / Child Abuse
Drunk Driving / Traffic Violations

BANKRUPTCY
Sheriff Sales / Foreclosures / Repossessions
Credit Repairs / Tax Liens

FAMILY
Divorce / Support
Alimony / Child Custody
Protection From Abuse
Visitation / Adoptions

BUSINESS
Contracts / Negotiations
Litigation
Start-ups / Financing
Collections

REAL ESTATE
Commercial – Residential
Buying / Selling
Settlements / Closings

TAX PROBLEM
IRS Disputes / Tax Fraud
Audits / Liens / Levies
Tax & Estate Planning

Wills, Estates & Trusts Social Security

FREE Consultation ERIK B. JENSEN, P.C. Attorneys At Law

215-546-4700 24 HOUR AVAILABILITY 800-522-6606
1528 Walnut St., Suite 1401 Philadelphia

មានអ្នកបកប្រែភាសាខ្មែរ

Rely On Over
26 Years Of Experience

WWW.ERIKJENSENLAW.COM
we have Khmer staff

Voun Lay, BS
Marketing Coordinator
267-738-7006

ជោគជតារាសីទាំង១២ប្រចាំឆ្នាំថោះ

ឆ្នាំជូត លោកអ្នកអាចនឹងមានការព្រួយបារម្ភច្រើន ព្រោះតែមានមនុស្សចេះតែតាមឈ្នានីស ឬពុំនោះសោតទេ ក៏អាចមានរឿងរ៉ាវដែលកើតឡើងដោយសារមនុស្សភេទផ្ទុយដែរ ដូច្នេះលោកអ្នកត្រូវមានការប្រុងប្រយ័ត្នឲ្យបានខ្ពស់ ។ បើជាអ្នកប្រកបមុខរបរកសិរីញ អាចនឹងមានការខាតបង់យ៉ាងធំ ដូច្នេះមិនគួរដាក់ទុនថ្មីឡើយ ។ រីឯបញ្ហាគូស្នេហ៍ច្រើនតែគោះតើយដាក់គ្នា ។

ឆ្នាំឆ្លូវ រាល់ការបំពេញការងាររដ្ឋ។ របស់លោកអ្នកនៅក្នុងពេលនេះមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សខ្លាត់ព្រាត់ឲ្យសោះ ព្រោះនាំឲ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ បើជាអ្នកប្រកបមុខរបរកសិរីញជលកម្រៃបានមកកាក់កប និងអាចសន្សំទុកបាន ។ រីឯបញ្ហាស្នេហាគឺគូស្នេហ៍មានស្តានភាពដូចធម្មតាទេ ។

ឆ្នាំខាល គ្រប់ការងារទាំងអស់ដែលលោកអ្នកត្រូវធ្វើ បើមិនអស់កម្លាំងសហការទេ គឺមិនអាចទទួលបានលទ្ធផលល្អឡើយ ហើយបើធ្វើដំណើរតាមយានយន្តលោក អ្នកគួរតែប្រុងប្រយ័ត្នខ្ពស់ជាងដែរ ចៀសវាងការកើតមានគ្រោះថ្នាក់ដោយប្រការណាមួយ ។ បើជាអ្នកប្រកបមុខរបរកសិរីញគួរជួញដូរនៅទីជិត ។ ទើបសមប្រកប ។ រីឯបញ្ហាស្នេហា គូស្នេហ៍ចេះស្តាប់ឱវាទគ្នា ។

ឆ្នាំថោះ លោកអ្នកមានការឈ្លាសវៃក្នុងការបំពេញការងាររដ្ឋ។ ដែលធ្វើឲ្យលោកអ្នកទទួលបានជលសម្រេចតាមគោលដៅដែលអ្នកច្រាថ្នាចង់បានយូរមកហើយ ។ បើ ជាអ្នកប្រកបមុខរបរកសិរីញ អាចមានគេមកបបួលដាក់ទុនរកស៊ីជាមួយដែលលោកអ្នកគួរប្រថុយចុះ ព្រោះមិនខកបំណងទេ ។ រីឯបញ្ហា គូស្នេហ៍រស់នៅជាមួយគ្នាប្រកបទៅដោយភាពផ្អែមល្ហែម ។

ឆ្នាំរោង រាល់ជលប្រយោជន៍ដែលខាតបង់ពីថ្ងៃមុននោះ មកដល់ពេលនេះអាចនឹងស្តារបានឡើងវិញ ខ្លះដាក់ជាពុំខាន ហើយសេចក្តីសុខចំរើនក៏កើតមានដល់លោកអ្នកជាដែរ ។ បើជាអាជីវករកសិរីញមានការរីកចំរើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ។

ឆ្នាំម្សាញ់ រាល់ការងាររបស់លោកអ្នកមានសភាពធ្លាក់ចុះមិនច្បាស់លាស់ ហេតុនេះទាមទារឲ្យលោកអ្នកមានការប្រយ័ត្នប្រយែង និងព្រុះពារឲ្យបានខ្លាំងជាបន្តទៀត ទើបអាចសម្រេចបានជោគជ័យ ។ បើជាអ្នកប្រកបមុខរបរកសិរីញ អាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហា គូស្នេហ៍រមែងចេះអត់ឱនឲ្យគ្នា ។

ឆ្នាំរកា គ្រប់កិច្ចការទាំងអស់ដែលលោកអ្នកស្រាវស្រែវជ្រាវបំពេញបានជលយ៉ាងគាប់ប្រសើរ ព្រោះមានអ្នកចាំជួយជ្រោមជ្រែងគ្រប់ពេលវេលា ។ បើជាអាជីវកររកសិរីញ អាចរកប្រាក់ចំណេញបានយ៉ាងច្រើន ហើយងាយស្រួលទៀតផងជាមួយនេះ ក៏អាចពង្រីកមុខរបរបានថែមទៀត ។ រីឯបញ្ហាស្នេហា គ្មានអ្វីគួរឲ្យកត់សំគាល់ឡើយ ។

ឆ្នាំច រាល់ការបំពេញការកិច្ចប្រចាំថ្ងៃ ទោះបីជាមានការធុញថប់ក្តីព្រោះមានអ្នកជួយជ្រោមជ្រែងគ្រប់ពេលវេលា ដូច្នេះលោកអ្នកមិនត្រូវអស់សង្ឃឹមឡើយ ។ បើជាអ្នកប្រកបមុខរបរកសិរីញ រកជលកម្រៃកាក់កបគ្រាន់បើ ថែមទាំងអាចសន្សំទុកដាក់បានខ្លះទៀតផង ។ រីឯបញ្ហាស្នេហា គូស្នេហ៍ច្រើល មើលបំណាំគ្នា ។

ឆ្នាំកុរ លោកអ្នកច្រើនជួបនឹងការបរាជ័យទាំងក្នុងការបំពេញការងារទាំងការចេញទៅទាក់ទងនៅក្រៅ ហើយបើមានការធ្វើដំណើរទៅទីណាមួយនោះក៏ត្រូវមានការប្រុងប្រយ័ត្នដែរ ។ បើជាអ្នកប្រកបមុខរបរកសិរីញ លោកអ្នកមិនគួរប្រថុយប្រថានដាក់ទុនធំពេកនោះទេ ព្រោះអាចនាំឲ្យមានការខាតបង់ ។ រីឯបញ្ហាស្នេហា គូស្នេហ៍ច្រើនពាក់មុខយកក្បាលដាក់គ្នាខុសទំនង ។

ឆ្នាំឆ្លូវ លោកអ្នកអាចនឹងមានមនុស្សភេទផ្ទុយ អាយុស្រាលគ្នាចាំប្តោលទោសទាញយកជលប្រយោជន៍ ឬពុំនោះសោតទេ ក៏ត្រូវចៅហ្វាយនាយស្តីបន្ទោសពីរឿងការងារ ។ បើជាអ្នកប្រកបមុខរបរកសិរីញ មុនឌឹងទូទាត់បញ្ជីលុយកាក់ គួរតែពិនិត្យជ្រៀងជ្រាត់ឲ្យបានម៉ត់ចត់ចៀសវាងការប្លោះឆ្លោយ ។ រីឯបញ្ហាស្នេហា មានការរកាំរកូសគ្នា តែមិនឆ្ងល់ឆ្ងែរ ។

ឆ្នាំមមី លោកអ្នកអាចនឹងត្រូវចៅហ្វាយនាយ ឬមេការប្រកាន់ថ្នាក់ និងស្តីបន្ទោសមិនបណ្តាក់មាត់ ឬើយបើពុំនោះសោតទេ ក៏អាចមានការទាស់ទែងខ្វែងគំនិតគ្នាជាមួយញាតិពន្ធ ដែលជាអ្នកជិតស្និទ្ធផងដែរ ។ បើជាអ្នកប្រកបមុខរបរកសិរីញអាចត្រូវខាតដើមដោយចៀសពុំរួចនោះទេ ដូច្នេះលោកអ្នកមិនគួរចោះទុនធំឡើយ ។ រីឯបញ្ហាស្នេហាច្រើនកើតរឿងឈ្លោះប្រកែកគ្នា ដោយសារអ្នកដទៃ ។

ឆ្នាំវក លោកអ្នកអាចនឹងត្រូវមនុស្សសម្បុរសមកបញ្ចុះបញ្ចូលចិត្តឲ្យដើរទៅរកផ្លូវមិនល្អ ហេតុនេះបើសិនជាមានមែនទោះ ចូរកុំរវើរវាយជាមួយឲ្យសោះ ព្រោះអាចបណ្តាលឲ្យមានក្តីវិនាសអន្តរាយដល់ខ្លួនបាន ។ បើជាអ្នកប្រកបមុខរបរកសិរីញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តី គួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឲ្យខាតបង់ ។ រីឯបញ្ហាស្នេហា គូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ។

ឆ្នាំមែ លោកអ្នកអាចនឹងត្រូវចៅហ្វាយនាយ ឬមេការប្រកាន់ថ្នាក់ និងស្តីបន្ទោសមិនបណ្តាក់មាត់ ឬើយបើពុំនោះសោតទេ ក៏អាចមានការទាស់ទែងខ្វែងគំនិតគ្នាជាមួយញាតិពន្ធ ដែលជាអ្នកជិតស្និទ្ធផងដែរ ។ បើជាអ្នកប្រកបមុខរបរកសិរីញអាចត្រូវខាតដើមដោយចៀសពុំរួចនោះទេ ដូច្នេះលោកអ្នកមិនគួរចោះទុនធំឡើយ ។ រីឯបញ្ហាស្នេហាច្រើនកើតរឿងឈ្លោះប្រកែកគ្នា ដោយសារអ្នកដទៃ ។

ឆ្នាំខ្លែ លោកអ្នកអាចនឹងត្រូវមនុស្សសម្បុរសមកបញ្ចុះបញ្ចូលចិត្តឲ្យដើរទៅរកផ្លូវមិនល្អ ហេតុនេះបើសិនជាមានមែនទោះ ចូរកុំរវើរវាយជាមួយឲ្យសោះ ព្រោះអាចបណ្តាលឲ្យមានក្តីវិនាសអន្តរាយដល់ខ្លួនបាន ។ បើជាអ្នកប្រកបមុខរបរកសិរីញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តី គួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឲ្យខាតបង់ ។ រីឯបញ្ហាស្នេហា គូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ។

ឆ្នាំជូត លោកអ្នកអាចនឹងមានការព្រួយបារម្ភច្រើន ព្រោះតែមានមនុស្សចេះតែតាមឈ្នានីស ឬពុំនោះសោតទេ ក៏អាចមានរឿងរ៉ាវដែលកើតឡើងដោយសារមនុស្សភេទផ្ទុយដែរ ដូច្នេះលោកអ្នកត្រូវមានការប្រុងប្រយ័ត្នឲ្យបានខ្ពស់ ។ បើជាអ្នកប្រកបមុខរបរកសិរីញ អាចនឹងមានការខាតបង់យ៉ាងធំ ដូច្នេះមិនគួរដាក់ទុនថ្មីឡើយ ។ រីឯបញ្ហាគូស្នេហ៍ច្រើនតែគោះតើយដាក់គ្នា ។

ចោកឈុតក្នុងចាយៗតែថ្ងៃល្អ

●រឿងចោកជម្រះឈុតក្នុងនេះ គឺទាមទារឲ្យបានស្អាត តែទន្ទឹមគ្នានោះដែរ ក៏ត្រូវធ្វើការក្បាយាមមិនអន់ប៉ុន្មានដែរ ទើបធានាបានទាំងសុវត្ថិភាព និងគុណភាព ។ តទៅនេះ គឺជាវិធីសម្អាតឈុតក្នុងបែបងាយ ហើយធានាថាមានប្រសិទ្ធភាពបំផុត ។

●គួរបំបែកខោអាវឈុតក្នុង និងឈុតក្រៅមុនពេលចោករាល់លើក ។

●គួរប្រើម្យ៉ាសាប៊ូលាយនៅក្នុងទឹកជាមុនសិន ឬអាចប្រើប្រភេទសាប៊ូដែលតម្រូវឲ្យប្រើជាមួយខោអាវឈុតក្នុង ។ មិនគួរប្រើសាប៊ូ ឬប្រើអូសារ៉ែលគ្រប់ប្រភេទចោកឈុតក្នុងដាច់ខាត ។

●ចោកដោយដៃថ្នម។ មិនណែនាំឲ្យប្រើប្រាស់ដុសដែលអាចធ្វើឲ្យធាប់យារខូច ។

●គួរចោកជម្រះទឹកសាប៊ូឲ្យបានច្រើនទឹករហូតដល់មានទំនុកចិត្តថាជ្រះជាតិសាប៊ូអស់ ។

●គួរហាលឈុតក្នុងនៅក្នុងទីម្លប់ និងមានខ្យល់បក់ខ្លាំង ។ មិនគួរហាលនៅកណ្តាលកំដៅថ្ងៃក្តៅ ព្រោះអាចធ្វើឲ្យឆ្លុកពណ៌ និងខូចគុណភាព ។

សោភ័ណភាព

អាំងពោតឲ្យមានសេជាតិឆ្ងាញ់

●●●ពោតអាំងប្រសិនបើអ្នកអាំងដោយមិនយល់ពីអាថ៌កំបាំងវាទេ នោះសាច់ពោត

របស់អ្នកនឹងមានសភាពក្រៀមរឹងដូចពោតទុំថែមទាំងគ្មានរសជាតិទៀតផង ។ ដើម្បីឲ្យពោតអាំងរបស់អ្នកមានឱជារសធ្ងាញ់ជាប់ចិត្តដំបូង សូមច្របាច់យកក្បាលខ្ទិះដូងទៅលាយជាមួយស្ករ និងអំបិលឲ្យមានរសជាតិប្រៃផ្អែម ។ បន្ទាប់មកយកផ្លែពោតទៅជ្រលក់ត្រាំនៅក្នុងទឹកនោះទើបដាក់អាំងរហូតដល់ឆ្អិន ។ លើកនេះធានាថា សាច់ពោតអាំងរបស់អ្នកមិនត្រឹមតែមានរសជាតិឈ្ងុយ ហើយធ្លាក់ប៉ុណ្ណោះទេ វាថែមទាំងមានសាច់ជ្រាយទន់ជាងទំពាទៀតផង ។

កំចាត់រុយដោយម្ទេសក្រៀម

●នរណាៗក៏ទទួលស្គាល់ថា សត្វរុយ គឺជាសត្វប្រភេទដែលចម្លងនូវមេរោគបានយ៉ាងងាយបំផុតដែរ គឺវារោមតែរបស់ណាដែលស្មោកគ្រោក ធ្វើឲ្យមេរោគជាប់នៅតាមជើងរបស់វា ហើយចម្លងមកកាន់មនុស្សនៅពេលវាមកទុំលើចំណីអាហារដែលយើងត្រូវទទួលទាន ។

សត្វរុយនេះក៏ជាសត្វខ្មាន់ដល់ស្ត្រីមេផ្ទះខណៈពេលនាងធ្វើម្ហូបអាហារប្រចាំថ្ងៃទៀតផង ។ ក៏ប៉ុន្តែ ប្រសិនបើចង់ដោះស្រាយរឿងនេះ នោះគឺជាការងាយបំផុតដោយគ្រាន់តែ សូមណែនាំឲ្យស្ត្រីមេផ្ទះនាងយកម្ទេសក្រៀមប្រហែល៥-៦គ្រាប់យកទៅដោតសៀតនៅជុំវិញកញ្ចែង សាច់ឬបន្លែ ឬក៏កញ្ចែងដែលដាក់ហាលសាច់ជាដើម នោះសត្វយក៏តជាពុំហ៊ានមកក្បែរខ្មាន់ទៅទៀតឡើយ ។

ប្រជុំកោះស្ប្រាតីឡីស៍ (SPRATLEYS)

ដោយ : គីម វិមល

"នាវាចំបាំងដឹកយន្តហោះប្រតិកម្មចិន បានចេញបង្ហាញខ្លួនលើទីលានប្រយុទ្ធ?"

មេទ័ពជើងទឹកចិនបានឱ្យដឹងប្រាប់ការសែតហុងកុង ថា





នាវាដឹកយន្តហោះចម្បាំង យើងត្រូវបានសាងសង់ចប់ហើយ ប៉ុន្តែវាពុំទាន់ចប់សព្វគ្រប់នោះទេ! លោក មេទ័ព ចេន ប៊ីង គិតថាដល់ចប់សព្វគ្រប់មែនទែន "នាវា នេះនឹងបង្ហាញខ្លួនវាឱ្យច្បាស់ជាងនេះទៀត"។ នាវា ចម្បាំង វ៉ារីយ៉ាក់នេះ ត្រូវបានទិញពីប្រទេសយូក្រែន កាលពីឆ្នាំ១៩៩៨ ហើយពេលសព្វថ្ងៃនេះ វាឈប់សំចតនៅ ផៃទាហានជើងទឹកឈ្មោះ ដាលីយ៉ង់ (Dalian)។ ពួកអ្នកជំនាញយោធាបានប៉ាន់ស្មានថា នាវាចម្បាំងរបស់ ចិននេះ "ច្បាស់ជានឹង ធ្វើសកម្មភាពជើងទឹក នារដូវស្លឹកឈើ ធ្លាក់ខាងមុខមិនខាន។ សព្វថ្ងៃ គេទុកវាប្រើប្រាស់ក្នុងការ បង្ហាត់ហ្វឹកហ្វឺនកងកម្លាំងជើងទឹករបស់ចិន។

ពិសេសជាងនេះទៅទៀត គេអាចយល់ថាទីក្រុងប៉េកាំង និងសម្រេចសាងសង់នាវាចម្បាំងដឹកយន្តហោះដោយខ្លួនឯង នាបញ្ចប់ឆ្នាំ២០២០នេះតែម្តង។ ហើយគេ នឹងចាប់ផ្សើបចំបង្កើតកម្លាំងជើងទឹក ដោយសាងសង់បណ្តានាវាចម្បាំង ដែលមិនហួសពីប្រាំមួយម៉ឺនតោនទេ និងចំនួនពាភាគ៨ថ្មីទៅ នៅដែនយោធាចាន់ឈេរ៉ឹងជិតក្រុងស្បៃងហៃ។ ចំណែកមេទ័ព ស.រ.អា គឺលោក រ៉ូប៊ែរ វីឡារ៉ឺ (Roberi Willars) យល់ថា "នាវានេះ ពិតជា បានផ្លាស់ប្តូរយុទ្ធសាស្ត្រយោធាក្នុងតំបន់ពិតមែន!"។

"ចិនហាមស.រ.អា មិនឱ្យមកដេកស្រមុកនៅក្បែរត្រែដំណេកចិន!"

បណ្តាក្រុមអ្នកជំនាញយោធាតំបន់ប៉ាស៊ីហ្វិក ច្បាស់ជឿថាសង្គ្រាមផ្លូវទឹកនឹងអាច កើតមាននៅតំបន់ឈូងសមុទ្រចិនមិនខាន។ ប៊ង់តាហ្គោន បានបង្កើតសេចក្តី ព្រមានចិនថា: "ដោយពុំមានគោលការណ៍ត្រឹមត្រូវយើង ខ្លាចថាជ្រៀសមិនផុតពីជម្លោះ ជាយថាហេតុនោះទេ! ក្នុងតំបន់ដែលដែនទឹក កំពុងពេញទៅដោយជម្លោះ"។ រ៉ូប៊ែរ ហ្គេត បន្ថែមទៀតថា "គួរតែគេប្រញាប់ប្រញាល់រៀបចំ តុបតែងច្បាប់ពហុភាគីមួយទុកដោះស្រាយជាហេតុដែល អាចកើតមានឡើង"។ រដ្ឋលេខាធិការក្រសួងការពារជាតិស.រ.អា បានបញ្ជាក់ថា ស.រ.អាគិតថា ពង្រឹងកម្លាំងជើងទឹកក្នុងតំបន់អាស៊ីនេះ "ដោយយុទ្ធភ័ន្ធចំនើប១ទៀតផង"។ ជាមួយគ្នានេះចិនបានបំពងសម្លេងដង្ហើយឱ្យគេនាំគ្នា "គោរពអ្វីៗដែលជាអាយុជីវិតរបស់គេម្តាក់ៗ ព្រមទាំងការពារ ឧត្តមប្រយោជន៍របស់គេ"។ គឺការបំបែកកម្លាំង សន្ធប់លើចិន។ តែយល់ថាចិនច្បាស់ជា

តទៅទំព័រទី១៨

ជាក់ខ្លួនតម្រង់តាម គំនូសប្រវត្តិសាស្ត្រ (LETRACE DES 9 POIVTS) ដែលបាន ត្រូវបន្សល់ទុកឱ្យប៉េកាំង ដោយពួកចិនស្នេហាជាតិ និយម Kuomintang Sonkaset។ ហើយដែលបណ្តាលឱ្យប៉ះពាល់ ដ៏ធ្ងន់ធ្ងរយ៉ាយលើឆ្នេរណេភាព នៃប្រទេសក្នុងតំបន់ទាំងអស់ (អត់តែខ្មែរ ម្នាក់?!)។ គំនូសប្រវត្តិសាស្ត្រ គឺត្រូវបានទុក "ឱ្យយើងសព្វថ្ងៃ" ដោយពួក គូមីងតាំងតែប៊ុក៏ បើផ្អែកលើសំដីលោកមេទ័ព លាង ប៊ីន។

ក្រុមអ្នកជំនាញយោធាសំខាន់ម្ល៉ាងទៀតថា ក្រុងប៉េកាំងអាចចាត់ទុកថា នាវាជំនួញទាំងប៉ុន្មានក្នុងតំបន់ ជាគូរភាគីសំខាន់បំផុតសម្រាប់គេ។ លើយនាវារបស់គេ សុទ្ធតែលាបពណ៌សនិងផ្ទុកដោយអាវុធគ្រប់ៗគ្នាផង។

"កុំមកដេកស្រមុកក្បែរត្រែអញ!"

សំគាល់បាននូវស្ថានការណ៍ពីរយ៉ាង។ ការយល់ដឹងពីបញ្ហាដែនសមុទ្រ និងនៅចំពោះមុខច្បាប់អន្តរជាតិ ជួយៗគ្នាទៅវិញ។ ម្ខាងយល់ថា គោលការណ៍អ.ស.ប វាគ្រប់គ្រាន់ណាស់ទៅហើយ ក្នុងការចរចារប្រកបដោយ ភាពទូលំទូលាយណាមួយអំពីដែនសមុទ្រ ដែលមានប្រកបដំណាក់ផ្សេងៗ។ ក៏ប៉ុន្តែចិនបានយល់ព្រមត្រឹមតែរក្សាគោលការណ៍ចាស់លំដាប់ណាស.រ.អា និងប្រទេសផ្សេង១ឯទៀត កុំមកទន្ទ្រានដេកស្រមុកជិតក្បែរតំបន់សេដ្ឋកិច្ចផ្តាច់មុខ (ZEE= zone economiqu exclusive) ឱ្យសោះ។

សូមរំលឹកថា កាលពីខែមិនា ២០០៩ គេឃើញមានការប៉ះទង្គិចគ្នា ម្តងរួចទៅហើយរវាងចិន និងស.រ.អា (USNS Impeceable) នៅតំបន់ហៃណាង (HAINAN)។ ទោះជាយ៉ាងណា ស.រ.អា បានទទួលស្គាល់ថា កងល្បាតជើងទឹកចិន ពុំបានឆាវឆៅការងារខ្លួនទេ ប៉ុន្តែក្រុងប៉េកាំងបានព្រមានថា "កុំមករកជ្រកដេកស្រមុកក្បែរត្រែ ដំណេករបស់យើង" បើយោងតាមយុទ្ធសាស្ត្របុរាណកាលរបស់ពពួក រាជវង្សសុង (DYVASTIS SONG)។

ខេនី ត្រូវទេមន្តដោយសម្មាធិ

មើលជម្ងឺនានា, ដោះមន្តស្នេហ៏, រំដោះគ្រោះ, ជួយគ្រួសារបែកបាក់,
មើលមុខរបររកស៊ី, ហុងស៊ុយ, ធ្វើយ័ន្តការពារខ្លួន។
ចេះមន្តអាគមតាមរបៀប ចិន, យួន, ចាម ។
បើចង់ដឹងបន្ថែមសូមទំនាក់ទំនងតាមរយៈទូរស័ព្ទ:
(540) 397-2603 ខ្ញុំឈ្មោះ "KENNY"

Psychic Readings by Nancy offers a variety of services to help you find answers to the questions that are on your mind and the issues you're most concerned about. Nancy will use her gift to help you through your journey.

Learn More About Psychic Readings by Nancy:
• Tarot cards • Palm readings
• Aura cleansing • Astrology • Speacializes in business affairs • Stop break-up, divorce, and infidelity

Private phone readings for the convience of your own home, please call
I am available for appointments, or walk-ins.
Contact Psychic Readings by Nancy today at
978-930-3503
for more information.

ការិយាល័យមេធាវី ដឺរិច ឌីង ប៊ូស្តី
LAW OFFICE DOERING & BOROWSKY, LLC

ទទួលការពារជូនប្រយោជន៍លោកអ្នក ករណីទូទៅតាមផ្លូវច្បាប់ដូចជា :



. ករណីបើរបរពាណិជ្ជកម្ម និងផ្ទេរប្រាក់ក្នុងមុខជំនួញ
. ករណីទិញលក់អចលនវត្ថុ ដូចជាផ្ទះសម្បែង ដីធ្លីជាដើម
. រើសអើងនៅកន្លែងធ្វើការ
. ករណីអន្តោប្រវេសន៍

ធ្លាប់មានបទពិសោធន៏ខ្ពស់ _ផ្តល់សេវាជីនតាមវិជ្ជាជីវៈហើយតម្លៃក៏សមរម្យ ទៀតផង _យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។

General practice law office handing matters in :
Corporations and business Transations
Real Estate
Work Place discriminations
Immigration
Experienced, professional service and reasonable rate Interpreter available

Office: (215) 667-8118 1650 Market st. Ste 3600 Philadelphia, PA 19103
Cell: (215) 840-1364; Email: dblawyers@gmail.com

បំណុលទិញបញ្ជាការសែតខ្មែរប៊ុស្តិ៏
ឈ្មោះ និងអាស័យដ្ឋានរបស់

ឈ្មោះ :.....
អាស័យដ្ឋាន : .....

ខ្ញុំចង់ជាវ :

☐ កាសែតខ្មែរប៊ុស្តិ៏ ១ខែ មាន២លេខ ៦ខែ $30 ១២ខែ $60 ឬ $70 អឺរ៉ូ សម្រាប់អឺរ៉ុប
☐ សៀវភៅឈ្មោះ .....តម្លៃ $.....
☐ ស៊ីឌីប្រវត្តិសាស្ត្រខ្មែរ ៤ ម៉ោង ម្លៃមួយសិត $30
ខ្ញុំភ្ជាប់សែក ឬ មនីអដ័រ មក U.A.M.G តម្លៃ $.....
ផ្ញើមក U.A.M.G 438 LINDLEY AVE. PHILADELPHIA, PA 19120
Phone : 267-253-3947

Massachusetts Council on
Compulsive Gambling

We understand the problem. We can help.

ក្រុមប្រឹក្សារដ្ឋម៉ាសាឈូសេតសំរាប់
ការញៀនល្បែងស៊ីសង

"ប្រសិនបើលោកអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់
មានបញ្ហាញៀនល្បែងស៊ីសង សូមទូរស័ព្ទមកលេខ
ខាងក្រោម អាចជួយជាអ្នកសម្ងាត់ ហើយ
សូររកសៀវភៅសម្រាប់ឱ្យអាចជួយខ្លួនឯងបាន
ជាភាសាខ្មែរដោយឥតគិតថ្លៃ"

1-857-383-3577

ដំបូន្មានរបស់អ្នកគ្មានទៅកាន់ការផ្តាស់ប្តូរ

www.asianproblemgambling.org

NEW
CHINA PEARL
DIM SUM (All Day, EveryDay)

288 Mishawum Rd., Woburn, MA 01801
Phone:(781) 932-0031/Fax: (781) 932-0346
www.NewChinaPearl.com
From Boston 95 South; Exit 37B, from Lowell
93 South; Exist 37B, from RT-128; Exit 36.

ភោជនីយដ្ឋានញូឆាយណាភើលសូមអញ្ជើញលោកអ្នក
និងក្រុមគ្រួសារមកភ្លក់រសជាតិម្ហូបអាហារមកពី
ហុងកុង និងប្រទេសអាស៊ីនានាជុំវិញ។យើងមានសាលកំ
សាន្តសំរាប់ ពិធីការ ឬការជួបជុំគ្នាមានបា និងខារ៉ាអូខេ
ទៀតផង កន្លែងចតឡានមិនយកថ្លៃ ហើយមានសុវត្ថិភាពល្អ ។

新龍鳳大酒樓

ZAGAT RATED
ZAGAT
ZAGAT.COM

Very Good to Excellence Food,
Boston Restaurants,
2011/2012"

Restaurant & Bar
ភោជនីយដ្ឋាន និងបា

ភោជនីយដ្ឋាន ញូ ឆាយណា ភើល

Ballrooms for Wedding & Party
មានឆាកវាំសំរាប់ពិធីការ ឬប្រជុំកំសាន្ត

ការ៉ាអូគី Karaoke
Thursday – Saturday Night
8 p.m. – 11:45 p.m.

មានឌិនស៊ុមរាល់ថ្ងៃ DAILY DIM SUM
Weekdays: 11 a.m.–3 p.m.
Weekends: 10 a.m.-3 p.m.

BUSINESS HOURS: Mon – Wed 11 a.m. – 10 a.m./Thurs. & Fri. 11 a.m. - 12 Midnight / Sat. 10 a.m. - 12 Midnight / Sun. 10 a.m. – 10 p.m. Delivery Hours 11 a.m. – 9 p.m. min. $15 order plus $2 delivery.



COMMUNITY OF KHMER BUDDHIST MONKS USA FUTURE TEMPLE SITE

SITE 1 - 104 TOWNSEND AVE./ SITE 2 - 800.1 VARNUM AVE./ SITE 3 - 810 VARNUM AVE.
LOWELL, MA 01852

PREPARED BY 4SQUARES BUILDING DESIGN
& D.P EVERS ARCHITECTURE

មជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរ ស.ខ.អ.
Community of Khmer Buddhist Monks Center U.S.A.
P.O. BOX 653
North Chelmsford, Massachusetts 01863
Tel: (978) 251-2709, Fax: (978) 251-1198
www.ckbm.org

លិខិតថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអគ្មាភាព ព្រះសង្ឃាធិបតី **សៅ ឃន** *(ធម្មវេរៈ) ប្រធានសហគមន៍ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិក (CKBM) សូមនមស្សការព្រះថេរានុត្តេរៈគ្រប់ព្រះអង្គជាទីគោរព និង ចម្រើនពរញាតិញោមពុទ្ធបរិស័ទ សប្បុរសជនទាំងឡាយជាទីគប់អាន ។*

កាលពីថ្ងៃអាទិត្យ៨កើត ខែស្រាពណ៌ ឆ្នាំថោះ ត្រីស័ក ព.ស. ៦៥៥៥ ត្រូវនឹងថ្ងៃទី៧ ខែសីហា ឆ្នាំ២០១១ កន្លងមកនេះ, សហគមន៍ព្រះសង្ឃខ្មែរ ដោយមានការនាំទ្រពីពុទ្ធបរិស័ទនិង សប្បុរសជនទាំងឡាយ បានរៀបចំបុណ្យផ្កាប្រាក់សាមគ្គីមួយ នៅគោជនីយដ្ឋានសំពៅមាស ទី ក្រុងឡូវ៉ែល រដ្ឋម៉ាស្សាជូសេត ដើម្បីប្រមូលបច្ច័យសម្រាប់ជួយឧបត្ថម្ភ ដល់តម្លៃជាដើមសាងវត្ត ធ្វើជាមជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិក ។ នៅថ្ងៃបុណ្យផ្កាប្រាក់សាមគ្គីនោះ គឺជាព្រឹត្តការណ៍មួយប្រកបដោយមោទនភាព និងកិត្តិយសខ្ពង់ខ្ពស់ក្រៃលែង ដោយមានព្រះ សង្ឃ ញាតិញោមពុទ្ធបរិស័ទ សប្បុរសជន និងអ្នកមុខអ្នកការ បានទិមន្តនិងអញ្ជើញមកពីរដ្ឋ ម៉ាស្សាជូសេត រដ្ឋរ៉ូដអាយឡែនដ៍ រដ្ឋម៉ែន ទីក្រុងញូយ៉ក រដ្ឋខនិតធិទិត រដ្ឋកាលីហ្វ័រនៀនិងរដ្ឋនីស៊ី និងរដ្ឋផ្សេងៗទៀត ពិសេសពុទ្ធបរិស័ទទីក្រុងឡូវ៉ែល និងទីក្រុងលីន សរុបជាង១០០០នាក់ បាន ទិមន្តនិងអញ្ជើញចូលរួម ក្នុងពិធីបុណ្យនោះយ៉ាងច្រើនកុះករដែលមិនធ្លាប់មាន ។ ពិធីបុណ្យផ្កា ប្រាក់សាមគ្គីនេះ បានទទួលលទ្ធផលបច្ច័យសរុបចំនួន $127,462 ដុល្លារ និង 50 អឺរ៉ូ (ដប់ពីរម៉ឺន ប្រាំពីរពាន់ បួនរយ ហុកសិបពីរដុល្លារ និងហាសិបអឺរ៉ូ) ។

ជាមួយគ្នានេះ, ខ្ញុំព្រះករុណាអគ្មាភាព ក៏សូមប្រគេននិងជម្រាបពត៌មាន ឲ្យបានជ្រាប ផងដែរថា សហគមន៍ព្រះសង្ឃខ្មែរ បានជាវដីមួយកន្លែងមានទំហំ 12 អេកឺ (ជិត5ហិកតា) ស្មើ និងផ្ទៃដី 48,572 ម៉ែត្រក្រឡា ស្ថិតនៅក្នុងក្រុងឡូវ៉ែល រដ្ឋម៉ាស្សាឈូសេត ក្នុងតម្លៃមួយលាន ដុល្លារសហរដ្ឋអាមេរិក ។ សូមបញ្ជាក់ថា ដីវត្តនេះជាកម្មសិទ្ធិរបស់សហគមន៍ព្រះសង្ឃខ្មែរ ដែល ត្រូវបានចុះព្រះហស្តលេខាលើកិច្ចទទួលសិទ្ធិ (Deed) គ្រប់គ្រង់ កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដោយព្រះសង្ឃជាមហាថេរៈចំនួន ១០ អង្គ ។

ក្នុងនាមប្រធានសហគមន៍ព្រះសង្ឃខ្មែរ ខ្ញុំព្រះករុណាអគ្មាភាពសូមសម្តែងនូវកតញ្ញូតា ធម៌ និងការគោតសរសើរដោយស្មោះអស់ពីដួងចិត្ត ព្រមទាំងសូមថ្លែងអំណរគុណយ៉ាងជ្រាល ជ្រៅ ចំពោះព្រះថេរានុត្តេរៈគ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទសប្បុរសជនទាំងអស់ ដែល បានចូលរួមឧបត្ថម្ភគាំទ្រ ក្នុងពិធីបុណ្យផ្កាប្រាក់សាមគ្គីកន្លងមកនេះ ក៏ដូចជាការជួយគាំទ្រ ដល់របបកកម្ម របស់សហគមន៍ព្រះសង្ឃខ្មែរកន្លងមក និងទៅអនាគតផងដែរ ។

សហគមន៍ព្រះសង្ឃខ្មែរ សូមប្រសិទ្ធិពរដ៏ឃសិរីសួស្តីមហាប្រសើរ ប្រគេននិងជូនដល់ ព្រះថេរានុត្តេរៈគ្រប់ព្រះអង្គ ញាតិញោមពុទ្ធបរិស័ទនិងសប្បុរសជនទាំងអស់ នូវពុទ្ធពរទាំង ឡាយ ៦ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសម្បត្តិ៣ មនុស្ស ទេវតា និងព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

ធ្វើនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១១

ប្រធានសហគមន៍ព្រះសង្ឃខ្មែរ **សៅ ឃន** *(ធម្មវេរៈ)*